អ្នកស្រី យ៉ីម នីម៉ូណា ជាប់ជ័យលាភីលេខ១ ផ្នែកប្រលោមលោក ពានរង្វាន់មហោស្រពអន្តរ២០០០

សេចក្តីថ្លែងអំណរគុណ

ចជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ សូមថ្លែងអំណរគុណជ៖ជ្រាលជ្រៅ ចំពោះអង្គការ អុកស្វាមេរីកា និងអង្គការ ប៉ាឌីក ដែលបានជួយឧបត្ថម្ភក្នុងការរៀបរៀង និងបោះពុម្ពទស្សនាវដ្ដីលេខនេះ ។

Acknowledgment

Khmer Women's Voice Centre would like to express its deepest thanks to OXFAM GREAT BRITAIN AND PADEK who are financially assisting the whole expense for making this issue

តំកល់ទុកតាមច្បាប់ អនុញ្ញាតរបស់ក្រសួងពត៌មានលេខ ១៤១_៤៣ ចុះថ្ងៃទី ០៦_១២_៤៣

ទស្សនាវដ្ដីចម្រុះភាសា. ខ្មែរ_អង់គ្លេស

Bilingual magazine : Khmer and English

1/2000

ខែ ធ្នូ ២០០០

សម្លេងស្ត្រីខ្មែរ

Khmer Women's Voice



ជ្រាក់កំរែបន្ថែមម៉ោង មិនទាន់បានត្រឹមត្រូវ

លេខ 4-8

អង្គការសម្លេងស្ត្រីខ្មែរ

published by Khmer Women's Voice Centre

ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ Khmer Women's Voice Magazine		មាតិកា Contents	ទំព័រ Page
គណៈកម្មការនិពន្ធ	**Writers Committee**	មាតិកា	0
		អារម្ភកថា Preface	1
អ្នកស្រី កុយ វេត	Ms Koy Veth	ជូនពរបុណ្យចូលឆ្នាំសកល និងសហស្សវត្សរ៍ថ្មីឆ្នាំ២០០០	2
អ្នកស្រី សុិម ចាន់យ៉ា	Ms Sim Chanya	**ទស្សនៈ** -កាលបើមានតែសមភាព	3
អ្នកស្រី សារ៉ី នីថា	Ms Sary Nitha	-If Only Equality Existed	4
អ្នកស្រី យីម នីម៉ូឡា	Ms Yim Nimola	**ច្បាប់** -ច្បាប់ការងារ ជំពូកទី៦ ស្តីពីការលុបចោលនូវការងារ	5
		-ប្រាក់កំរៃម៉ោងបន្ថែម មិនទាន់ចានត្រឹមត្រូវ	6
អ្នកអ្សៀចអ្សៀង	**Editor**	**សុខភាព :** -ពេលដែលត្រូវមានកូន	8
អ្នកស្រី សុិម ចាន់យ៉ា	Ms Sim Chanya	**សុវត្ថិភាព :** -ត្រូវគេចោកយកទៅលក់២ដង	9
		-Twice Cheated into Prostitution.	10
អ្នកវាយកុំព្យូទ័រ	**Computer Typist**	-ជ:ទឹកអាស៊ីដ ! អ្នកណាខ្លះជាអ្នកខុស?	12
អ្នកស្រី សារ៉ី នីថា	Ms Sary Nitha	-.អង្គការ CCHDO	14
កញ្ញា ព្រំ សុជាតិ	Ms Prum Socheat	-CCHDO Organization	16
អ្នកជំនួយការ	**Consultant**	**វប្បធម៌ :** -.អ្នករក្សាវប្បធម៌ខ្មែរនៅទល់ដែន	18
លោក យ៉ាន រូស្សូ	Mr Yann Rousseau	-រង្វាន់លេខ១ សហស្សវត្សរ៍ថ្មី	20
		ពត៌មាន	22
		សុជីវធម៌	25
អ្នកត្រួតពិនិត្យភាសាអង់គ្លេស	**English checker**	**ម្ហូបចំណី**	26
លោក ចន យេលសុន	Mr John Kelson	**ជួបជាមួយអ្នកមានវិបត្តិ**	27
		ជួបជាមួយមិត្តអ្នកអាន	28
		កំប្លែង	29
		កវីនារីលេខ២ -The Second-ranked Poetess	30 32

អាសយដ្ឋាន: ផ្ទះលេខ៩៤ ផ្លូវ៤៧០ សង្កាត់ទួលទំពូង I ខ័ណ្ឌចំការមន ភ្នំពេញ
ប្រអប់សំបុត្រលេខ៥៩០ ទូរស័ព្ទ និង ទូរសារលេខ (០២៣)២១ ២៣ ៥២
Address: Khmer Women's Voice Centre #94, St.470, Toul Tompoung I, Chamkar Mon, Phnom Penh
P.O Box : 590, Phone-Fax : (023)21 23 52, Email : seametr@forum.org.kh

អារម្ភកថា

"សម្លេងស្ត្រីខ្មែរ" គឺជាទស្សនាវដ្ដីផ្សាយចេញពីមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ ដែលជា"អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក" មួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ យើងខ្ញុំ មានទិសដៅជំរុញស្ត្រីភេទអោយចូលរួម និងសំរេចការងារទាំងឡាយលើវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងជំរុញអោយសង្គមទទួលស្គាល់តួនាទី និងការចូលរួមនោះ ដោយយើងខ្ញុំសង្កេតឃើញថា មកដល់បច្ចុប្បន្ននេះ ស្ត្រីនៅកម្ពុជាពុំទាន់មានលទ្ធភាពទទួលបានរាល់សិទ្ធិដែលមានចែងក្នុងច្បាប់នៅឡើយ និងដោយយើងខ្ញុំឃើញទៀតថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានការខ្វះខាតជាខ្លាំងនូវឯកសារដែលលើកឡើងអំពីបញ្ហាស្ត្រីភេទ ទើបយើងខ្ញុំផ្ដួចផ្ដើមអោយមានទស្សនាវដ្ដីនេះឡើង។

ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ មានទិសដៅអភិវឌ្ឍន៍ស្ត្រីខ្មែរលើផ្នែកស្មារតី សតិអារម្មណ៍ បញ្ញា ការយល់ដឹង។ ដើម្បីសំរេចបានទិសដៅនេះ ទស្សនាវដ្ដីលើកឡើងពីការលំបាក បំណងប្រាថ្នា និងមតិយោបល់មួយចំនួនរបស់ស្ត្រីខ្មែរ ជូនចំពោះគ្រប់ស្ថាប័នមានសមត្ថកិច្ច មាន ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលជាដើម ដើម្ប៊ ធ្វើសំណូមពរសូមអោយមានដំណោះស្រាយណាមួយសមស្រប។

ជាមួយគ្នានេះដែរគណៈកម្មការនិពន្ធ ខិតខំតាក់តែង និងប្រមូលរាល់អត្ថបទណាដែលគណៈកម្មការយល់ថា អាចជួយឧបត្ថម្ភ ស្ត្រីលើផ្នែកស្មារតី គឺបំផុសនិងជំរុញស្ត្រីអោយមានចំណេះដឹងទូលាយ ជឿជាក់លើសមត្ថភាពខ្លួន កសាងចិត្តគំនិតរឹងប៉ឹង ក្លាហានឈានឡើងជានិច្ច ដើម្បីអោយគេបានរួមចំណែកខ្លាំងក្លាក្នុងការកសាងប្រទេសជាតិ។

សម្លេងស្ត្រីខ្មែរ ក៏មានគោលបំណងជងដៃរ អប់រំ ណែនាំសង្គមជាតិទាំងមូលអោយលុបបំបាត់ចោលនូវទស្សនៈខុសឆ្គងចំពោះស្ត្រីភេទ កាត់បន្ថយការរើសអើងចំពោះស្ត្រី ខំថែរក្សាប្រពៃណីយើងល្អ និងខិតខំបង្កើតទស្សនៈណាដែលត្រឹមត្រូវចំពោះស្ត្រី។

គណៈកម្មការនិពន្ធ សូមស្វាគមន៍ជានិច្ចចំពោះគំនិតយោបល់ មតិវិភាគ ស្តាបនា និងមតិយោបល់របស់អស់លោក លោកស្រី នាងកញ្ញា ហើយយើងខ្ញុំរង់ចាំទទួល និងចុះផ្សាយជូនលទ្ធ ផលអត្ថបទណាមួយ ដែលមានខ្លឹមសារស្របនឹងទិសដៅខាងលើរបស់អស់លោក លោកស្រី នាងកញ្ញា។

PREFACE

Khmer Women's Voice Magazine is prepared by Khmer Women's Voice Centre, a local NGO in the Kindom of Cambodia.

Khmer Women's Voice Centre promotes participation and decision making by women in social, economic, and political spheres while influencing the society to reconize the role and contribution of women.

At the present time, in Cambodia women do not have the opportunities to have equal rights with men yet, as stipulated in the different laws, and documents treating women issues are scarce. The magazine was created to address these needs.

Khmer Women's Voice magazine contributes to the personal development of women with articles dealing with spirituality, knowledge and intelligence. The magazine presents the desires difficulties and opinions of Khmer Women to the institutions concerned where the appropriate solutions will be made.

The committee of writers gathers existing texts or writes its own texts which challenge women and encourage them to have confidence in their capacity to participate actively in the building of the country.

Khmer women's Voice magazine also attempts to educate the whole society by eliminating harmful and incorrect preconceptions about women, reducing discrimination against women, promoting developing traditions and disseminating points of views which are good for women. The committee of writers welcomes all your feedback and would be pleased to receive and print only texts which contribute to meeting the objectives.

ជូនពរបុណ្យចូលឆ្នាំសកល និងសហស្សវត្សរ៍ថ្មី

ឆ្នាំ២000

បុគ្គលិកទាំងអស់

នៃ

មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ

សូមគោរពថ្វាយនិងជូនពរភ្ជួនឱកាសឆ្លងសហស្សវត្សរ៍ថ្មី
ព្រះករុណាជាអម្ចាស់ជីវិតកំពស់លើភ្ជួង
និងសម្តេចព្រះរាជអគ្គមហេសី

លោកជំទាវ សម្តេច ឯកឧត្តម លោកស្រី អ្នកនាងកញ្ញា អស់លោកក្នុងស្ថាប័នរដ្ឋ និងឯកជនទាំងអស់ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសស្ត្រីខ្មែរទាំងអស់ នៅក្នុងប្រទេសនិងក្រៅប្រទេស សូមបានប្រកបតែសេចក្ដីសុខ សុភមង្គល រីកចំរើន ក្នុងភារកិច្ចនិងជីវភាព ដើម្បីរួមចំណែក ជួយស្តារមាតុភូមិកម្ពុជា

គិតណែនាំ

កាលបើមានតែសមភាព

នៅក្នុងគ្រប់ច្បាប់ទាំងអស់ក្នុងប្រទេសកម្ពុជាយើង ស្រីនិងប្រុសមានសិទ្ធិស្មើគ្នា នៅចំពោះមុខច្បាប់ រាប់តាំងពីការសិក្សា ការបណ្តុះបណ្តាល ការព្យាបាលនៅមន្ទីរពេទ្យ ការកាន់កាប់ដីធ្លី ការប្រកបមុខរបរអាជីវ ការដើរឡើងឋានៈតួនាទី។ មិនដែលមានសាលារៀនណាកំណត់ថា អនុញ្ញាតអោយតែសិស្សប្រុសចូលរៀន មិនអនុញ្ញាតអោយសិស្សស្រីនោះទេ មិនដែលមានអង្គភាពណាកំណត់ថា ផ្នាក់ដឹកនាំត្រូវតែជាបុរស មិនយកភេទស្រីនោះទេ។ ដូច្នេះឃើញថាជាទូទៅ សមភាពមានគ្រប់គ្រាន់នៅក្នុងច្បាប់ ក្នុងប្រទេសកម្ពុជាយើង។

ក៏ប៉ុន្តែក្រឡេកមើលការពិតជាក់ស្តែងវិញ ស្ថានភាពស្ត្រីខ្មែរមិនទាន់ប្រសើរឡើយ។ យើងអាចលើកឧទាហរណ៍ជាក់ស្តែងមួយចំនួន។ កុមារីខ្មែរ ជាពិសេសនៅជនបទភាគច្រើនរៀនត្រឹមតែពីរឆ្នាំប៉ុណ្ណោះ ឪពុកម្តាយអោយឈប់ដើម្បីជួយធ្វើកិច្ចការផ្ទះ។ នៅមធ្យមសិក្សា សិស្សស្រីចូលរៀន មានតែ ៣៥% ហើយនៅឧត្តមសិក្សា សិស្សស្រីមានតែ ១០ទៅ១៥%ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងចំនួនសិស្សទាំងអស់។ ក្នុងការទទួលឋានៈជាអ្នកដឹកនាំនៅតាមមូលដ្ឋាន ក៏ដូចក្រសួងមន្ទីរ ស្ត្រីមានចំនួនតិចបំផុត។ នៅព្រឹទ្ធសភា មានស្ត្រី ៧រូបក្នុងចំណោមសមាជិកសរុប៥៥រូប , រដ្ឋសភា មានសមាជិកស្ត្រី១២រូបក្នុងចំណោមសមាជិកសរុប១២២រូប រដ្ឋមន្ត្រី មានស្ត្រី២រូប ក្នុងចំណោម រដ្ឋមន្ត្រីសរុប២៥រូប រដ្ឋលេខាធិការ មានស្ត្រី៤រូប ក្នុងចំណោមរដ្ឋលេខាធិការសរុប៥០រូប អនុរដ្ឋលេខាធិការ មានស្ត្រី៥រូប ក្នុងចំណោមអនុរដ្ឋលេខាធិការសរុប១៣២រូប មេឃុំ ចៅសង្កាត់ មានស្ត្រីច្រើនជាង១០រូប ក្នុងចំណោមមេឃុំសរុប ១៦២៣រូប។ ស្ថានភាពបែបនេះ បញ្ជាក់អោយឃើញថា សមភាពដែលមាននៅក្នុងច្បាប់ ពុំមានពិតប្រាកដក្នុងសង្គមឡើយ។ ដូច្នេះឃើញថា ជាការពិតប្រយោជន៍ កាលបើមានត្រឹមតែសមភាពនៅក្នុងច្បាប់ ។ តើត្រូវធ្វើយ៉ាងណា អោយសមភាពនេះ ក្លាយទៅជាការពិតជាក់ស្តែងក្នុងសង្គម? ។ គឺលុះណាតែមាន "សមធម៌" ផ្ទៃមទ្យើត។

សមធម៌ គឺជាការបង្កលក្ខណៈគ្រប់បែបយ៉ាង ដើម្បីធ្វើយ៉ាងណាជំរុញសមភាពអោយអនុវត្តបានជោគជ័យ។ ដើម្បីអោយយល់ច្បាស់រឿងនេះ យើងសូមលើកយករឿងព្រេងមួយមកនិទាន។ សត្វកុកនិងកញ្ជ្រោងជាសំលាញ់នឹងគ្នា តែមានគំនិតមិនស្មោះត្រង់នឹងគ្នាឡើយ។ ថ្ងៃមួយសត្វកុកអញ្ជើញសំលាញ់ទៅជប់លៀង តែកុកបានរៀបចំម្ហូបអាហារដាក់ក្នុងថូ ដែលមាន ក រ ។ លុះដល់ពេលហូបអាហារ កុកហូបតែម្នាក់ឯង រីឯកញ្ជ្រោងពុំអាចហូបបានឡើយ ព្រោះម្ហូបទាំងអស់ដាក់នៅក្នុងថូ។ សត្វកុក និងសត្វកញ្ជ្រោង មានសមភាពនៅក្នុងការហូបអាហារ តែគ្មានសមធម៌ឡើយ។ អ្នកទាំងពីរមានសិទ្ធិស្មើៗគ្នានៅចំពោះមុខការហូបអាហារ តែអ្នកដែលអាចហូបបាន មិនមែនទាំងពីរនាក់ទេ គឺមានតែម្នាក់ប៉ុណ្ណោះ។ ដូច្នេះបើចង់អោយកញ្ជ្រោងហូបបានផង ត្រូវបង្កលក្ខណៈងាយស្រួលដល់កញ្ជ្រោង គឺត្រូវដាក់ម្ហូបអាហារនៅលើមានទាប នោះហើយ ដែលហៅថា មានសមធម៌ផងដែរ។

យ៉ាងណាមិញ បញ្ហាស្ត្រីបុរសនៅក្នុងសង្គម ក៏មិនខុសគ្នាដែរ។ បើគេគ្រាន់តែផ្តល់ត្រឹមតែសមភាព តែខ្វះសមធម៌ ដែលមានន័យថា ការ ជួយបង្កលក្ខណៈ ក៏ស្ត្រីពុំអាចទាញយកផលប្រយោជន៍ អ្វីបានពីសមភាពនោះឡើយ។ ដើម្បីអោយអាចផ្តល់សមធម៌បាន តើយើងត្រូវធ្វើយ៉ាងណា?

ចំពោះបញ្ហានេះ យើងមិនមែនចេះតែនាំគ្នាថាមកពីនេះ មកពីនោះ ដោយគ្មាន មូលដ្ឋានឡើយ។ ជាដំបូងគួរតែយើងនាំគ្នាធ្វើការស្រាវជ្រាវ រិះរកមូលហេតុពិត ឧបសគ្គពិត ដែលបណ្តាលអោយកើតហេតុការណ៍នេះសិន ដើម្បីអោយដឹងថា តើមកពីអ្វី? ពីអ្នកណា? ពីស្រី? ពីប្រុស? ពីសង្គម? ពីប្រពៃណី? ពីអ្នកដឹកនាំ? ។ លុះស្រាវជ្រាវរកឃើញឧបសគ្គពិតហើយ ទើបយើងរិះរកវិធីណាសំរាប់រំលាយឧបសគ្គនោះ នោះហើយ ទើបហៅថា ផ្តល់សមធម៌ដល់ស្ត្រីភេទ។

អ្នកស្រី សុិម ចាន់យ៉ា

If Only Equality Existed

Under Cambodian law both men and women are equal in study, training, medical treatment at hospitals, land tenure, doing businesses, promotion of social ranks,etc. No schools admit only schoolboys and exclude schoolgirls and no government deparments or units define that the leaders of their institutions must be men and not women. Therefore, it can be seen that equality edequately really exists under Cambodian laws.

But what has just been mentioned above is quite contrary to the real current situation. The situation of Khmer women is not sufficiently. This can be seen in the following examples. Most Khmer girls, especially those in the rural areas, are able to go to school for at most three or four years. Their parents then ask them to quit their studies in order to help with the farm work or the housework. Only about 35% of girls are reportedly learning at secondary schools and only 10% or 15% of them are at higher educational levels. There are only a few women assuming the positions of leadership in local and government institutions. In the senate, there are only 7 women out of 59 senators. There are 12 women out of 122 national assembly members. There are two women ministers in twenty five, and four women Secretaries of State out of 132. There are no more than 10 women who are communal and Sangkat chiefs out of 1,623. This clearly shows that equality exists only in law, but not in society. So it really becomes useless if equality exists only in the law. What should we do to materialize equality in our society? Only when true equality exists can it be achieved.

Equity is the provision of all sorts of favorable conditions aimed at encouraging equality to be crowned with success. In order to make it understandable, we would like to tell you a folk-tale: Once there was a fox and a heron. They were both friends, but they were not faithful to each other. One day, the heron invited his friends, the fox, to have a meal at his home. The heron prepared good food, but he put it in a long-neck vase. During the meal the heron ate alone. The fox was unable to eat because the food was put in a the vase with a long neck. This shows that the heron and the fox both enjoyed equality in having the meal, but not equity. They both had equal rights in having their meal, but only one of them could enjoy eating the meal. Therefore, if the heron had wished the fox to enjoy his meal, he would have provided the fox with more favorable conditions, such as putting the food on a plate.

The moral of this story is no different from what is happening in our Khmer society. If women are only allowed to enjoy equality, but not equity, surely they can not benefit from such equality. So what should we do to enable women to enjoy equity? First of all, we should uncover the root causes and the true obstacles which have brought all these things about, in order to know what has caused them and who has caused them. Has everything been caused by men or women, by society, by tradition or by the leaders? Only after we have unearthed the root causes of these things can we devise better ways to make obstacles disappear. Only then can we provide equity for women.

Ms Sim Chanya

សូមមេត្តាផ្ដល់យោបល់ ទិតៀនស្ថាបនា ឬសំណូមពរផ្សេងៗ
ចំពោះទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ
Please send us your feedbacks or your suggestions

ច្បាប់
ស្តីអំពី
ច្បាប់ការងារ

ជំពូកទី៦
លក្ខខ័ណ្ឌទូទៅ នៃការងារ
ផ្នែកទី៣
ការងារនៅពេលយប់

មាត្រា១៤៤.

ពាក្យថាយប់ក្នុងច្បាប់នេះមានន័យថា រយៈពេលដប់មួយម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង២២ ទៅម៉ោង៥ក្លឹងង ។

ក្រៅពីការងារបន្តបន្ទាប់ដែលក្រុមកម្មករផ្ដាស់វេនគ្នាធ្វើការ ជួនថ្ងៃ ជួនយប់ ការងារនៃសហគ្រាសអាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច ។ ការងារពេលយប់ត្រូវអោយឈ្នួល តាមអត្រាដែលកំរិតក្នុង *មាត្រា១៣៩* នៃច្បាប់នេះ ។

មាត្រា១៣៩.

ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតា តម្រូវអោយកម្មករនិយោជិត ធ្វើការបន្ថែមក្រៅម៉ោង ពេលធម្មតា ម៉ោងពេលបន្ថែមទាំងនេះ ត្រូវអោយឈ្នួលតាមអត្រាតម្លើងហាសិបភាគរយ ។ ប្រសិនបើធ្វើការបន្ថែមនៅពេលយប់ ឬនៅថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ ត្រូវផ្ដល់ប្រាក់បន្ថែម តាមអត្រាតម្លើងមួយរយភាគរយ ។

(នៅមានត)

ប្រាក់កំរៃម៉ោងបន្ថែម មិនទាន់បានត្រឹមត្រូវ

ថ្ងៃឆ្ងាន្ត្រនេះ ឧស្សាហកម្ម រោងចក្រកាត់ដេរ បានតើតឡើងដូចឫស្សីតក្លាតនឹកស្ងៀង បន្ទាលតួណ:ចាយស្រួលដល់ប្រជាពលរដ្ឋយើងមានការងារធ្វើ ជាពិសេស នារីមានលទ្ធភាពច្រើនជាងមុនសិទ្ធ ប៉ុន្តែទន្ទឹមគ្នានឹងការតែកចំណែកនេះ ក៏មានបាតុភាពអសកម្មជាច្រើន បានចោទជាបញ្ហាឡើងដែរ។



កម្មករ កម្មការិនី រោងចក្រកាត់ដេរស្បែកជើងនៅផ្លូវបែកកូម កំពុងធ្វើបាតុកម្ម
កាលពីថ្ងៃទី១៤-១៥ ខែធ្នូ ឆ្នាំ១៩៩៩ នៅមុខរោងចក្រ

មិនបានផ្ដល់ក៏រំពេលកម្ម សមស្របតាមច្បាប់ការងារឡើយ

នាងគន្ធា(ឈ្មោះនេះមិនពិតទេ ដោយមិនហ៊ានបញ្ចេញឈ្មោះ) ធ្វើការនៅរោងចក្រកាត់ដេរ ជាង១ឆ្នាំហើយ បាននិយាយទាំងសំដីអន់ចិត្តថា ប្រាក់ខែរបស់នាងបានតែ៤០ដុល្លារ ស្មើនឹង១៥២.000រៀល។ ក្នុង១ខែ នាងត្រូវធ្វើការ១៥២ម៉ោង ដូច្នេះបើយកប្រាក់ខែនេះ មកគិតជាកំរៃក្នុង១ម៉ោងវិញ ឃើញថានាងទទួលបាន៧៥១រៀល។ ចំពោះការងារបន្ថែមក្រៅម៉ោង ច្បាប់ការងារ មាត្រា១៣៥ចែងថា លើកម្មករនោះ ធ្វើការបន្ថែមក្រៅម៉ោងក្នុងថ្ងៃធ្វើការធម្មតា នោះរោងចក្រត្រូវអោយកំរៃតាមអត្រាតម្លើងហាសិបភាគរយ តែបើកម្មករនោះ ធ្វើការបន្ថែមក្រៅម៉ោងក្នុងថ្ងៃឈប់សំរាកឬ ពេលយប់ នោះរោងចក្រត្រូវអោយកំរៃ តាមអត្រាតម្លើង មួយរយភាគរយ។ បើគិតប្រៀបធៀបនឹងច្បាប់នេះ ឃើញថា កំរៃប្រាក់បន្ថែមក្រៅម៉ោង ដែលនាងបានទទួលទាំងក្នុងថ្ងៃធម្មតា ទាំងពេលយប់និងថ្ងៃឈប់សំរាកមិនបានត្រឹមត្រូវទេ ព្រោះក្នុងថ្ងៃធម្មតាប្រាក់កំរៃធ្វើការបន្ថែមក្រៅម៉ោងរបស់នាង បានតែ១000រៀលប៉ុណ្ណោះ ក្នុង១ម៉ោង ដែលតាមពិត នាងត្រូវបាន ១១ដ៦រៀល រីឯក្នុងពេលយប់និងថ្ងៃឈប់សំរាកវិញ ប្រាក់កំរៃធ្វើការបន្ថែមក្រៅម៉ោងរបស់នាងបានតែ១៤២៥រៀល ក្នុង១ម៉ោង(៣ដុល្លារ ក្នុង ១ថ្ងៃ)ដែលតាមពិតនាងត្រូវបាន១៥៨២រៀល។

នាងខេមា (ឈ្មោះនេះមិនពិតទេ) កម្មការិនីនៅក្នុងរោងចក្រ កាត់ដេរជាមួយគ្នា ក៏បានលើកឡើងដែរថា ចំពោះនាងផ្ទាល់ គ្រាន់តែមកធ្វើការមិនទាន់ម៉ោងតែមួយដងឬពីរដង ពួកគេដកចេញពីកន្លែងដេរអោយផ្ទាស់ទៅនៅកន្លែងកាត់ព្រួយអាវ ដោយទទួលបានប្រាក់ពលកម្មតែ ៣៥ដុល្លារ តិចជាងនៅកន្លែងដេរទៅទៀត។ ដូច្នេះបើគិតជាប្រាក់កំរៃម៉ោង ក្នុងមួយម៉ោង ៦៥២រៀល។ ឯប្រាក់កំរៃលើការងារធ្វើការលើសម៉ោងក្នុងថ្ងៃធ្វើការធម្មតា១ម៉ោង នាងទទួលបានមិនដល់១000រៀលទេ ដែលតាមពិតទៅនាងត្រូវទទួល១0៣៨រៀល។

នាងសិលា(ឈ្មោះនេះមិនពិតទេ) អាយុ ២២ឆ្នាំ ជាកម្មការិនី ក្រុមហ៊ុនទឹកសុទ្ធ បានសំដែងនូវការមិនពេញចិត្តចំពោះប្រាក់កំរៃប្រចាំខែថា ១ ខែនាងទទួលប្រាក់ពលកម្មតែ៤0ដុល្លារសំរាប់រយៈពេល៨ម៉ោងក្នុងមួយថ្ងៃ។ ដូច្នេះប្រាក់កំរៃពលកម្ម ក្នុងមួយម៉ោង ដែលនាងទទួលបានដូចកម្មការិនីរោងចក្រកាត់ដេរដែរ គឺ៧៥១រៀល។ ឯប្រាក់កំរៃ ដែលនាងធ្វើការបន្ថែមក្រៅម៉ោង ក្នុងថ្ងៃធ្វើការធម្មតាវិញក្រុមហ៊ុនផ្ដល់អោយ ដូចថ្ងៃធ្វើការធម្មតាដែរ គឺ៧៥១រៀលដដែល។ ចំពោះប្រាក់កំរៃ ក្នុងថ្ងៃបុណ្យនិងថ្ងៃឈប់សំរាកវិញ នាងត្រូវទទួលបាន១៥៨២រៀលទើបត្រឹមត្រូវតាមច្បាប់ប៉ុន្តែនាងពុំបានទទួលកំរៃដែលត្រឹមត្រូវនោះឡើយ។ ទោះជាយ៉ាងនេះក្ដីក៏នាងសុខចិត្តដែរ ព្រោះនាងគ្មានផ្លូវណាជ្រើសរើសអោយបានប្រសើរជាងនេះឡើយ។

នាងសុខចិត្តទទួលលុយ ដែលមិនទាន់ត្រឹមត្រូវតាមច្បាប់នេះ ជាជាងអត់ ដើម្បីបានយកទៅគួបផ្សំនឹងប្រាក់ខែដ៏ស្ពួចស្ពើងរបស់នាង។

ពតិមានទាំងអស់នេះ សុទ្ធតែបានផ្ដល់ពីកម្មការិនីទាំងអស់ ដោយការភ័យខ្លាច ព្រោះបើរោងចក្រដឹង ពួកនាងនឹងត្រូវគេបណ្ដេញចេញ មិនខាន។

> **បកពីខ្លាចគេដល់ល្បាចលែងអោយធ្វើការ ដោយសារ កម្មករ កម្មការិនីទាំងនោះ មិនហ៊ានប្ដឹងបក្សសហជីព ទោះបីរោងចក្រទាំងនោះ មិនផ្ដល់ប្រាក់កំរៃពេលកម្ម ដោយត្រឹមត្រូវតាមច្បាប់ការងារ ក៏ដោយ។**

ទាក់ទាញជ្ញាបាតុកម្ម

កម្មករ កម្មការិនី តែងតែនាំគ្នាធ្វើបាតុកម្ម ជាញឹកញាប់ ដូចជាកន្លង ទៅថ្មីៗនេះ នៅថ្ងៃទី១៤ ធ្នូ ១៩៩៩ កម្មករ កម្មការិនីរោងចក្រកាត់ដេរស្បែកជើង ក្រុមហ៊ុន អ៊ីនទីក ហ្ជូតវ៉ូ អ៊ិនដា ស្ត្រីកូ លីមីតធីត នៅអូរបែកកូម ចំនួន៧៥0នាក់ នាំគ្នាធ្វើបាតុកម្មប្រឆាំង និងអ្នកទទួលខុសត្រូវ រោងចក្រម្នាក់ជាជនជាតិចិន ដែលបានយកស្បែកជើង វាយក្បាលកម្មការិនីឈ្មោះ ចែម ឆេង។ ទន្ទឹមនឹងនោះ ពួកគេ ក៏ទាមទារ អោយរោងចក្រផ្ដល់ប្រាក់ពលកម្ម ម៉ោងបន្ថែម អោយបានត្រឹមត្រូវ ដូចចែងក្នុងច្បាប់ការងារ។

សំណូមពរចំពោះរាជរដ្ឋាភិបាល

កម្មករ កម្មការិនីទាំងអស់ សូមធ្វើសំណូមពរដល់រាជរដ្ឋាភិបាល និងក្រសួងដែលពាក់ព័ន្ធ ជាពិសេស ក្រសួងសង្គមកិច្ច សូមមេត្តាចុះត្រួតពិនិត្យប្រាក់ពលកម្មតាមរោងចក្រ ព្រោះរាល់ថ្ងៃនេះ អ្នកគ្រប់គ្រងទាំងនោះ កំពុងជិះជាន់និងកេងប្រវ័ញ្ច លើប្រាក់ពលកម្ម កម្មករ កម្មការិនីទាំងនោះ នៅឡើយ។ កម្មករ កម្មការិនី ធ្វើការនៅរោងចក្រកាត់ដេរទាំងនោះ ក៏បានលើកបញ្ជាក់ដែរថា បច្ចុប្បន្ននេះ លក្ខខ័ណ្ឌនៃការងារតាមរោងចក្រ ត្រូវបានកែលំអជាបណ្ដើរៗ។ មានការគោរពពេលម៉ោង និងថ្ងៃបុណ្យជាតិផ្សេងៗ ដោយសារមានការចុះធ្វើអធិការកិច្ច ពីសំណាក់ក្រសួងសង្គមកិច្ច។

នៅមានរោងចក្រមួយចំនួនធំ មិនទាន់អនុវត្តច្បាប់នេះនៅឡើយ

ឯកឧត្ដម អ៊ុ មាន អគ្គនាយកការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៃក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានមានប្រសាសន៍ថា កន្លងមកក្រសួងសង្គមកិច្ច បានណែនាំអោយនិយោជកគ្រប់រោងចក្រទាំងអស់ ធ្វើតាមច្បាប់ការងារដែលបានចែង ប៉ុន្តែនៅមានរោងចក្រមួយចំនួនធំ មិនទាន់អនុវត្តច្បាប់បាននៅឡើយ។ ម្យ៉ាងទៀត រោងចក្រនីមួយៗ តែងតែមានប្រធានសហជីព ប្រចាំរោងចក្ររបស់ខ្លួន ឬក៏ប្រតិភូក្រុម ចំពោះរោងចក្រដែលមិនទាន់មានសហជីព សំរាប់ជួយដោះស្រាយរាល់អំពើជិះជាន់ទាំងឡាយពីអ្នកដឹកនាំរោងចក្រ។ ដូច្នេះ បើមានបញ្ហាអ្វីកើតឡើង កម្មករ កម្មការិនីទាំងនោះ មានសិទ្ធិប្ដឹងទៅប្រធានកម្មករសហជីព ហើយប្រធានសហជីពនោះ ធ្វើពាក្យបណ្ដឹងមកក្រសួងសង្គមកិច្ច ក្រសួងនឹងចាត់ក្រុមអធិការកិច្ច ដែលទទួលខុសត្រូវផ្នែកនេះ ទៅពិនិត្យនិងធ្វើការដោះស្រាយជូនដល់កម្មករ កម្មការិនីទាំងនោះ តាមផ្លូវច្បាប់។

ប្រសិនបើ កម្មករកម្មការិនីប្ដឹងបក្សសហជីព

ចំណែកលោក ភូង មច្ឆ្ម ប្រធាននាយកដ្ឋានពតិមាន និងគ្រប់គ្រងធ្វើប័ណ្ណសមាជិក នៃសហជីពសេរីកម្មករ នៃ ព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា តាមលោកដឹងកន្លងមក ទោះបីកម្មករ កម្មការិនីទាំងអស់ទទួលការគាបសង្កត់ពីពួកនិយោជកយ៉ាងណាក៏ដោយ ក៏ពួកគេមិនហ៊ានធ្វើពាក្យបណ្ដឹងមកក្រសួងសង្គមកិច្ចដែរ ព្រោះមានការគំរាមកំហែងពីអ្នកដឹកនាំរោងចក្រទាំងនោះថា បើហ៊ានតវ៉ាតតាមប្រឆាំង គេនឹងបណ្ដេញចេញ លែងអោយធ្វើការ។ ម្យ៉ាងទៀត មកពីកម្មករ កម្មការិនីទាំងនោះ មានកំរិតយល់ដឹងទាបធ្វើអោយពួកគេកាន់តែភ័យខ្លាចថែមទៀត ម្ល៉ោះហើយ ចេះតែទ្រាំៗធ្វើទៅ។ លោក ភូង មច្ឆ្ម បាននិយាយបន្ទន្ទៀតថា បើកម្មករ កម្មការិនី ទាំងនោះ នាំគ្នាប្ដឹងដល់ក្រុមសហជីពរបស់លោក ទោះបីមិនបានគ្នាច្រើន មានត្រឹមតែ២ឬ៣នាក់ ក៏ដោយ ក៏ពួកលោកនឹងជួយប្ដឹងបន្ត ទៅក្រសួងសង្គមកិច្ចដាមិនខាន។

អ្នកស្រី សារី ឌីថា

សុខភាព

ពេលដែលត្រូវមានកូន

ទាំងបុរស ទាំងស្ត្រីចង់រស់នៅជាមួយគ្នា ដើម្បីអោយបានជាក្រុមគ្រួសារមួយ។ នេះមានន័យថា ស្ត្រីត្រូវមានសុខភាពល្អ។ ហើយរឿងនេះ ក៏មានន័យផងដែរថា ទាំងបុរសទាំងស្ត្រីយល់ដឹងថា ពួកគេអាចផ្ដល់នូវការថែទាំល្អ ចំពោះទារកបាន។

គូស្រករភាគច្រើនចង់បានកូនក្រោយពេលដែលគេរៀបការរួច។ គេចង់បានកូន ពីព្រោះគេចង់កសាងគ្រួសារមួយ ហើយបានរីករាយជាមួយកូនគេនៅក្នុងផ្ទះ។ ឪពុកម្ដាយនិងយកចិត្ដទុកដាក់ក្នុងការថែទាំកូន បើសិនជាគេមានចិត្ដចង់បានកូន។ ជាការសំខាន់ត្រូវអោយអ្នកទាំងពីរព្រមព្រៀងសំរេចចិត្ដថា ចង់បានកូនដូចៗគ្នា។ ក្រុមគ្រួសារនឹងមិនមានរីករាយក្នុងការមានកូនទេ បើសិនជាមានសមាជិកតែម្នាក់ដែលចង់បានកូន។ គូស្វាមី-ភរិយាអាចមានកូននៅពេលណាដែលគេចង់បាន ប្រសិនបើពួកគេដឹងនូវរបៀបដែលកូនកើត។ ចាស់ៗភាគច្រើនដឹងអំពីការចាប់បដិសន្ធិនៃកំណើត។ ទារកអាចចាប់មានកំណើត នៅពេលដែលបុរសស្ត្រីរួមដំណេកជាមួយគ្នា។ ប្រជាពលរដ្ឋខ្លះបានប្រើវិធីផ្សេងៗ ដើម្បីការពារកុំអោយមានកូន។ មនុស្សភាគច្រើន មានការខ្វាសអៀនក្នុងការនិយាយអំពីវិធីការពារកុំអោយមានកូននេះ។

តើនៅពេលណាដែលស្ត្រីគួរមានកូន?

ស្ត្រីគួរមានកូន នៅពេលណាដែលនាងមានសុខភាពល្អ។ បើស្ត្រីមានសុខភាពល្អ កូននោះក៏មានសុខភាពល្អដែរ។ ស្ត្រីគួរមានកូន នៅពេលដែលក្រុមគ្រួសារចង់បានកូន។ កូនដែលបានពីការស្រឡាញ់ពេញចិត្ដនឹងអាចទទួលនូវការថែទាំល្អ ហើយធំធាត់ឆាប់រហ័ស ដោយសុខភាពបរិបូណ៌។

ស្ត្រីគួរពន្យារពេល យ៉ាងតិចបំផុត ២ឬ៣ឆ្នាំ មុននឹងអោយមានកូនមួយទៀត។ ក្រោយពេលសំរាលកូនរួច កូនត្រូវការស្រឡាញ់ផ្ដាក់ផ្ដម ការថែទាំល្អ ដើម្បីធំធាត់រហ័ស។ កូនក៏ត្រូវការទឹកដោះម្ដាយ យ៉ាងតិចបំផុត២ឬ៣ឆ្នាំដែរ។

ខ្លួនប្រាណរបស់ម្ដាយ ក៏ត្រូវការពេលវេលាយ៉ាងតិច ២ឬ៣ឆ្នាំ ដើម្បីមានសុខភាពបរិបូណ៌ឡើងវិញ និងសំរាប់ការមានកូនក្រោយមួយទៀត។ ការមានកូនមានន័យថា មានកិច្ចការច្រើនណាស់សំរាប់រាងកាយស្ត្រី។ ចន្លោះពី២ទៅ៣ឆ្នាំ រវាងកូនមួយទៅកូនមួយ គឺជាការល្អចំពោះសុខភាពម្ដាយនិងកូន។ គួរស្រករ គួរគិតគួរអំពីការមានកូនមួយទៀត នៅពេលគ្រួសារមានលទ្ធភាព ជួយទំនុកបំរុងដល់កូនមួយទៀតនោះបាន។ ការមានកូនច្រើនថែមទៀត អាចមានន័យថា ធ្វើអោយសមាជិកម្នាក់ៗក្នុងគ្រួសារ បានទទួលរបបអាហារតិច ប្រសិនបើរបបអាហារនោះ និងធនធានមានកំរិត។

ស្ត្រីគួរតែពិភាក្សាជាមួយក្រុមគ្រួសារ មុនពេល ស្ត្រីមានកូនមួយទៀត។

ចំពោះអ្នកដែលបានសិក្សា អំពីការគ្រោះថ្នាក់របស់ស្ត្រី នៅពេលដែលស្ត្រីមានផ្ទៃពោះ។ ស្ត្រីបិតនៅក្នុងភាពគ្រោះថ្នាក់ អាចមានជម្ងឺជាទម្ងន់ឬរហូតដល់បាត់បង់ជីវិត នៅពេលដែលស្ត្រីមានកូនមួយទៀត។

ស្ត្រីគួរមានកូនមួយទៀត នៅពេលណាដែលដឹងថាខ្លួនមានសុខភាពល្អ។ បើស្ត្រីនោះមានជម្ងឺយូរយារមកហើយ ស្ត្រីគួរតែសាកសួរយោបល់ពីបុគ្គលិកសុខាភិបាលមុននឹងសំរេចចិត្ដថា ត្រូវមានកូន។

ដកស្រង់ពីសៀវភៅ "ការថែទាំក្មេងនៅផ្ទៃពោះ" មុនពេលសំរាលកូន របស់ក្រសួងសុខាភិបាល

សុខភាព

ត្រូវគេបោកយកទៅលក់ពីរដង

រឿងបោកប្រាស់ ផិតក្បត់ បក្ខិតបក្ខំ ចាប់រំលោភ បោកយកទៅលក់ គឺជារឿងសោកនាដកម្មនៃជីវិតរបស់ស្ត្រី តែចង់តែកើតឡើងជារៀងរាល់ថ្ងៃ ហានច្រើនដងទៀតរាប់មិនអស់ នៅតួចស្រួតខ្ជែរយើងៗ ករណីជាក់ស្ដែង ដូចជាតញ្ញា អាយុច្បាន់ត ត្រូវបានគេបោកយកទៅលក់អោយមេបានចំនួន២ដងបន្ដបន្ទាប់គ្នាៗ សព្វថ្ងៃ នាងកំពុងរស់នៅ តួចមណ្ឌលមួយរបស់អង្គការខេមរាៗ

ឆ្លាក់ខ្លួនស៊ីឈ្នួលគេ

ឆ្នាំ១៩៦ឆ្នាំ គឺជាវ័យកំពុងត្រូវការរស់ក្រោមការគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងដោយក្ដីស្រឡាញ់ផ្ដាក់ផ្ដមពីមាតាបិតាយ៉ាងកក់ក្ដៅ ទាំងការបូបចុក ការស្លៀកពាក់និងការរៀនសូត្រ ជាពិសេស ការផ្ដល់ដំបូន្មានល្អ១ និងការផ្ដល់កម្លាំងចិត្ដថែមទៀត។ ប៉ុន្ដែ ចំពោះកញ្ញា អាយុធ្យានុតវិញ នាងកំពុងបិតក្នុងស្ថានភាពលំបាកបំផុត ព្រោះនាងគឺជាក្មេងកំព្រាឪពុកម្ដាយ គ្មានផ្ទះសំបែង បងប្អូនសាច់ញាតិ រកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង។

ក្នុងទឹកមុខក្រៀមក្រំ ជាមួយគ្នានិងសំដីម៉ឹងម៉ាត់ បង្ហប់នូវក្ដីឈឺចុកចាប់ អាយុធ្យានុត បានរៀបរាប់ពីជីវិតខ្ជោចផ្សា របស់នាងថា មុនពេលនាងមកដល់ទីនេះ នាងបានឆ្លងកាត់ឧបសគ្គជាច្រើន ដែលមួយជីវិតនាង មិនដែលជួបប្រទះទាល់តែសោះ។

ក្រោយពីឪពុកម្ដាយនិងបងប្រុសស្លាប់ចោល នាងបានក្លាយជាក្មេងកំព្រា ហើយក៏ទៅស៊ីឈ្នួលជាំបាយអោយគេនៅក្នុងគ្រួសារមួយ នៅខេត្ដបាត់ដំបង។ មានថ្ងៃមួយ មានស្ត្រីចំណាស់ម្នាក់ បានមកបបួលនាងអោយទៅធ្វើការនៅភ្នំពេញ ដោយនិយាយថា កុំអោយនាងស៊ីឈ្នួលគេ វាពិបាកណាស់ ទៅធ្វើការនៅទីក្រុងភ្នំពេញទៅវាស្រួលជាង ហើយប្រាក់ខែច្រើនទៀត។ យុវតីក៏ជឿតាមគេភ្លាម ដោយមិនបានគិត ហើយម្ចាស់ផ្ទះដែលនាងនៅជាមួយ ក៏មិនបានឃាត់ដែរ គ្រាន់តែផ្ដាំថា ទៅធ្វើការភ្នំពេញមិនស្រួលប៉ុន្មានទេ ប្រយ័ត្នចាញ់បោកគេ។

ផ្ដួលក់ទៅកំពង់សោម ផ្ដួលក់ទៅកោះកុង

ជួចពាក្យម្ចាស់ផ្ទះនិយាយមែន អាយុធ្យានុត ត្រូវបានគេដឹកឡានបូសភ្នំពេញទៅក្រុងកំពង់សោម។ ជិះយូរទៅ១ មិនងាយដល់សោះ យុវតីក៏ដាច់ចិត្ដសួរទៅគេ ថាតើគេនាំនាងទៅណា ស្ត្រីចំណាស់នោះឆ្លើយថា ទៅធ្វើការកំពង់សោមវិញ ទើបសំបូរការងារធ្វើ នៅភ្នំពេញ ពិបាករកការងារធ្វើណាស់។ នៅពេលដែលកំពុងជិះលើឡាន អាយុធ្យានុត ងងុយបើកភ្នែកសឹងតែមិនរួច ហាក់ដូចជាត្រូវថ្នាំសណ្ដំគេ រហូតឡានបើកមកដល់ កន្ដែងពេជនិល ទើបស្វាងពីដេក។ ឡានក៏នាំនាងទៅដល់ទីកជីក្រុងកំពង់សោម ផ្ទះចូលកាន់តែជ្រៅទៅ១ ផ្ទះក្រលុកក្រលៀត រហូតដល់ផ្ទះមួយដែលមានបន្ទប់ច្រើន ហើយមានគ្រែគ្រប់បន្ទប់ទាំងអស់ គេអោយនាងចូលសំរាកក្នុងបន្ទប់ ដើម្បីសំរាកយកកម្លាំង។ ប្រហែលជាងមួយម៉ោងក្រោយមក ស្រាប់តែមានបុរសម្នាក់ដើរចូលមក អាយុធ្យានុត សួរបុរសនោះថា "ពួកឡាំ បន្ទប់ហើយ" ពួម្នាក់នោះឆ្លើយថា "មើលវាអញ្ជឹងអោយលុយហើយ វាធ្វើពើទៀត"។ ដោយការប្រកែកមិនយល់ព្រមតាមបំណងរបស់វា បុរសនោះក៏ខឹង ហើយដើរចេញទៅ ហៅថៅកែមកជួបនាង ថែមទាំងអះអាងថា ស្ត្រីនោះបានយកនាងមកលក់អោយថៅកែហើយ ដាច់ខាតនាងត្រូវតែទទួលភ្ជៀវ។ ពួកវាក៏បានអូសនាងចេញពីបន្ទប់ យកខ្សែភ្លើងបត់ជាបួនវាយវាត់នាងរហូតបែកឈាម។ តាំងពីពេលនោះមក អាយុធ្យានុត ចាប់ទទួលភ្ជៀវរហូត។ យុវតីកំសត់ខំសន្សំលុយដែលភ្ជៀវអោយក្រៅ ហើយក៏បានរត់គេចពីផ្ទះបនមកភ្នំពេញ តែចៃដន្យជិះឡានចំមនុស្សអាក្រក់ បានដាក់ថ្នាំសណ្ដំយកនាងទៅលក់អោយ

> **សូមអោយរដ្ឋាភិបាលមានវិធានការទប់ស្កាត់ភាពរំលោភបំពាន និងអនុវត្តច្បាប់អោយបានត្រឹមត្រូវ ដើម្បីជួយស្ត្រីនិងកុមារី កុំអោយធ្លាក់ចូលក្នុងភាពជាអ្នកលក្ខោះ ដូចសត្វអាតុំបែបនេះ។**

មេបននៅខេត្តកោះកុងទៀត។ លើកនេះ អាយុធ្យានុត បានព្យាយាមគេចខ្លួនម្តងទៀត នាងបានលូនចុះតាមប្រហោងក្តារ មកក្រោមផ្ទះ ដែលមានទឹកនិងស្រែមអានាម័យអណ្តែតត្រៀបត្រាព្រោះផ្ទះបននោះ សង់នៅលើបឹងកំណ្ហែ។ ម៉ោងប្រមាណ១ យប់ នាងបានរត់គេចមកតាមមាត់បឹង រួចទៅស៊ីឈ្នួលអូសបង្គាអោយគេ ដើម្បីយកលុយមកភ្នំពេញ។

ប្រសើរជាងរស់នៅក្នុងបន

ពេលឡើងជិះឡានទៅ ម្តងនេះ អាយុធ្យានុត មានអារម្មណ៍ភ័យខ្លាចជាខ្លាំង ព្រោះខ្លាចជួបមនុស្សអាក្រក់ទៀត តែសំណាងដែរ នាងបានមកភ្នំពេញដោយសុវត្ថិភាព។ ដោយគ្មានសាច់ញាតិបងប្អូននៅទីក្រុង នាងត្រូវទៅដេកកែ្បររបងវត្តបទុម បេះក្តីបអំពិលហូបជំនួសបាយ ព្រោះលុយដែលអូសបង្គាបានប៉ុន្មាន គ្រាន់តែគ្រប់សាប៊ីយជិះឡានប៉ុណ្ណោះ។ ពេលយប់ឡើង នាងសំរាកទាំងវេទនា ព្រោះតែដេកគ្មានមុង គ្មានខ្នើយ ដេកផ្ទាល់និងពន្ធ ដូច្នេះនាងត្រូវអង្គុយវាយមុសទាល់ភ្លឺ។ ប៉ុន្តែ ទោះជាពិបាកយ៉ាងនេះក៏ដោយ ក៏អាយុធ្យានុត ពេញចិត្ត នឹងជីវិតរស់នៅបែបនេះ ជាងរស់នៅក្នុងបនបំរើតែកាមគុណ អោយអាពូកណ្ណោតណ្ណាទាំងនោះដែរ។ ទាល់តំនិត មិនដឹងជ្រើសរើសផ្លូវ ណាអស់សង្ឃឹមក្នុងជីវិត អាយុធ្យានុត សំរេចចិត្តចូលទៅក្នុងវត្តបទុម ដើម្បីសុំយាយជីបួស ប៉ុន្តែ សំណាងល្អបានជួបបុរសម្នាក់ បាននាំនាងមករស់នៅក្នុងអង្គការខេមរា រហូតដល់សព្វថ្ងៃ។

ដោយសារតែបានរៀនភាសាអង់គ្លេសខ្លះ១ កាលនៅជាមួយឪពុកម្តាយ អាយុធ្យានុត ក៏បានសំណូមពារសូមអោយអង្គការខេមរា រកសាលាភាសាអោយ នាងបានរៀន ហើយនាងផ្ទាល់និងប្តេជ្ញាចិត្តរៀនទាល់តែចេះ ដើម្បីយកចំណេះ សំរាប់ចិញ្ចឹមជីវិតទៅថ្ងៃអនាគត។

អាយុធ្យានុត ក៏បានធ្វើការផ្តាំផ្ញើដល់នារី១ ដែលមិនទាន់ចាញ់ បោកគេ ត្រូវប្រុងប្រយ័ត្នខ្លួន ព្រោះមនុស្សអាក្រក់ មានល្បិចរាប់មិនអស់។ ចំពោះនារីដែលចាញ់បោកគេហើយ ត្រូវរិះរកមធ្យោបាយរំដោះខ្លួន ចេញពីកន្លែងលក់សាច់ឈ្មោលនេះអោយបាន។

ជាមួយគ្នានេះ កញ្ញាអាយុធ្យានុតបានសំណូមពារផងដែរ ទៅរដ្ឋាភិបាលថា "សូមអោយរដ្ឋាភិបាលមានវិធានការទប់ស្កាត់ភាពរំលោភ ច្បាប់និងអនុវត្តច្បាប់អោយបានត្រឹមត្រូវ ដើម្បីជួយស្ត្រីនិងកុមារី កុំអោយធ្លាក់ចូលក្នុងភាពរងគ្រោះដូចសត្វធាតុបែបនេះ"។

អ្នកស្រី សារ៉ា នីថា

Twice Cheated Into Prostitution

Being Cheated into prostitution, betrayed and raped by fathers, brothers or boy-friends, are all women's tragedies of life, which occur every day in Cambodia. Take as a real example: Ms Ayutyanuth was cheated and sold to brothels on two successive occasions. She is now living in a Khemara center.

She became a domestic helper

Ms Ayutyanuth is sixteen years old, an age which sorely needs guardianship, attention and, of course, much affection and encouragement from parents. In contrast, on reaching such an age Ms Ayutyanuth is a homeless orphan, has no relatives and has to do everything to feed herself.

With a sad look and firm remarks fraught with inexpressible sorrow, Ms Ayutyanuth bitterly and painfully related that before she came to live here she had undergone nume rous-hardships and met obstacles she had never before experienced.

She further said that she had become an orphan after her parents and her elder brother died. Then she was employed as a domestic helper in a family in B.Bang

province. One day an old woman came to try to lure her to come to work in P.Penh. The old woman told her that it would be easier for her to work in P.Penh as she would get more money. Without thinking things over, Ms Ayutyanuth quickly agreed with the old woman, and the house owner with whom she was then living did not try to stop her, but warned her to be very careful.

She was sold one time in Kompong Som another time in Koh Kong

Things happened just as her previous landlady had warned her. Instead of going to P.Penh, Ms Ayutyanuth was taken in a car bound for Sihanoukville. She eventually decided to ask the old woman where she was taking her. The old woman said it was easier to look for a job in Sihanoukville than in P. Penh. While in the car, Ms Ayutyanuth felt so sleepy that she could hardly open her eyes, as though she had been anaesthetized. It was not until the car arrived at a place called Pich Nil that she woke up. The car arrived in Sihanoukville and kept moving over bumpy dirt roads till it reached a house with many rooms which were all furnished with beds and fans. She was then told to rest in a room. After more than an hour, a man entered her room. Ms Ayutyanuth then told him that he had come into the wrong room. He said he had already paid and told her not to pretend. As she absolutely refused to fulfil his sexual desire, the man became furious and walked out of the room to tell the brothel owner about her refusal. The brothel owner then came and told her that she had been sold by the old woman, so she had to have sex with clients. The brothel owner's men dragged her out of the room and whipped her with electric cord. After that, Ms Ayutyanuth slept with every client. She tried to save some money secretly given by some generous clients and ran away from the brothel. Unfortunately, she rode in the car with bad people who again anaesthetized her and took her to Koh Kong province, where she was sold to a brothel again. This time, Ms Ayutyanuth escaped from this hell on earth by slipping down through a big hole in the floor where there were water and used condoms floating about as the brothel was built on a lake with water hyacinths. It was about one o'clock at night. She ran on and on along the lake and finally got to a shrimp farm where she got employment as a shrimp catcher. When she had some money, she decided to come to P.Penh.

Better than live in the brothel

As she got in a taxi, Ms Ayutyanuth felt very frightened because she was afraid of being cheated by bad people again. Luckily, she arrived in P.Penh safely. Because she had no relatives in the city, she had to spend the night beside the wall of Wat Botum Pagoda and ate green tamarind instead of cooked rice because her money was only enough to pay for the taxi fare. Throughout the whole night, she sat up driving away mosquitoes as she had no mosquito net and no pillow, and she wished it would be morning soon. In spite of such difficulties, Ms Ayutyanuth would rather live in such a state than live in the brothel to serve men's sexual desire. Having no choice, and despairing of life, Ms Ayutyanuth asked the nuns in Wat Botum Pagoda to let her become a nun. But fortunately, she met a good man who took her to live in this organization.

As she had learnt some English when she was with her parents, Ms Ayutyanuth requested the Khemara Organization to find a language school for her to continue her English. She was determined to study English well so that she could feed herself by using this knowledge in the future. Ms Ayutyanuth recommended that all the girls who have not yet been cheated be very careful because bad people have a lot of tricks. She also recommended the that girls who have already been cheated to try to escape from such dirty places.

Finally, Ms Ayutyanuth, with anguished heart, would like to request the Royal Government to take effective measures to crack down on the brothel owners and sextraffickers and to adopt an appropriate policy towards women and girls, thus preventing them from falling into such a despicable state.

Ms Sary Nitha

ស្ទង់ទស្សនៈ

ជ:ទឹកអាស៊ីដ! អ្នកណាខ្លះជាអ្នកខុស?

រឿងឃាតកម្មរបស់អ្នកស្រី ពិសិដ្ឋពិលិកា មិនធ្លាក់រកឃាតករយើញនៅ ស្រាប់តែមានរឿងប្ដូនប៉ងផ្ញើឃាតម្នាក់ទៀត ពើតលើកញ្ញា ភាត សារីណា ហៅស្រីអូន ជាការចំរៀងការអូខេ១ នាពេលក្រោយបានរងគ្រោះ ដោយការតាយជំនិតជ:ទឹកអាស៊ីដស្ទើរតែផ្ទុកជីវិត ពីលោកជំទាវជាអធិការរបស់ឯកឧត្តម ស្វាយ ស្ទឹងថា អនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ជាមួយនិងបុរសពីរនាក់ កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៩ កន្លងទៅថ្មីៗនេះ។ មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ បានធ្វើបទសំភាសជាមួយបងប្អូនប្រជាពលរដ្ឋមួយចំនួនជុំវិញរឿងរ៉ាវនេះ។

លោក សន ឆ្ឆា អ្នករត់ម៉ូតូឌុប

ខ្ញុំគិតថា គួរយើងស្រាវជ្រាវរកឫសគល់នៃបញ្ហាសិន។ ដែលអាចធ្លាក់ដល់ថ្នាក់នេះបាន គឺដំបូងមកពីអស់លោក១ ចូលចិត្ដស្វែងរកស្ត្រីក្មេងរូបស្អាត មកធ្វើជាគូកំណាន់ ព្រោះអស់លោកទាំងនោះ សំបូរ លុយកាក់ខ្លាំងពេក ចង់ស្វែងរកការសប្បាយអោយបានច្រើន ទោះបីជាការសប្បាយនោះស្នោកគ្រោក ខ្វះសីលធម៌ក៏ដោយ។ សព្វថ្ងៃនេះ អស់លោក១ កំពុងតែធ្វើតាមគ្នា ហាក់ដូចជាប្រលងប្រណាំងគ្នារកស្ត្រីក្មេងអោយបានមួយម្នាក់១ ។ ខ្ញុំថា បើមិនមានការកាត់បន្ថយគំនិតកខ្វក់នេះទេ អំពើហិង្សានៅតែកើតមានតទៅទៀត មិនខាន។

ខ្ញុំថា បើមិនមានការកាត់បន្ថយគំនិតកខ្វក់នេះទេ អំពើហិង្សានឹងនៅតែកើតមានតទៅទៀត មិនខាន១

អ្នកគ្រូ សំ សិន គ្រូបង្រៀននៅស្រុកកៀនស្វាយខេត្ដកណ្ដាល

រឿងចាក់ទឹកអាស៊ីដលើគេ គឺជាកំហុសមិនអាចប្រកែកបានទេ ប៉ុន្ដែខ្ញុំចង់អោយរដ្ឋាភិបាលយល់ថា បើមិនចង់អោយអំពើហ្នឹងកើតមានទៀត ទាល់តែកាត់បន្ថយផ្ទះបន ផ្ទះបា ខារ៉ាអូខេសិន ព្រោះកន្លែងហ្នឹងហើយដែលបណ្ដាលអោយកើតមានស្រីស្រា ផឹកស៊ីស្រីញី អូនបង មិនចេះចប់ ។ អោយតែមានអារបស់អស់ហ្នឹងហើយ ប្រាកដជានាំអោយប្រុស១បែកប្រាជ្ញាទៅខាងខ្ទេចហើយ តែខ្ទេចហើយ ប្រាកដជាកើតមានរឿងរ៉ាវ លោះគ្នាក្នុងគ្រួសារមិនខាន។

លោក ជា ជីម ជាប្រជាជននៅអូរ៉ូបែកក្ពរ

ស្រុកខ្មែរយើងឥឡូវ មានច្បាប់ហើយ ក៏ដូចអត់មានច្បាប់ ពួកគេនាំគ្នាសម្លាប់មនុស្ស ដូចជាសម្លាប់សត្វគ្មានកោតក្រែងច្បាប់ បន្ដិចសោះ ។ បើចាប់បានអ្នកប្រព្រឹត្ដខុសហើយ តែអ្នកនោះមានបក្សពួកឬមានសំណូកសូកប៉ាន់ គឺអ្នកទោសនោះអាចចេញពីការឃុំឃាំងភ្លាម ដូចជាករណីកញ្ញា ភាត សារីណា តារាចំរៀងកាវ៉ាអូខេ ត្រូវបានគេចាប់វាយធ្វើបាប និងជ:ទឹកអាស៊ីដថែមទៀត ទោះជាស្គាល់ឃាតការហើយក៏ដោយ ក៏នៅចាប់អ្នកទោសមកធ្វើទោសមិនបានទៀត ។

លោក ម៉ែម ឆុយហ៊ីសិ្ដ ធ្វើការនៅការិយាល័យ ភ្ជាំពេញប៉ុស្ដិ៍

យើងមានបញ្ហាពីរ ១-ផ្លូវច្បាប់ ២-ទាក់ទងនិងវប្ប:ធម៌របស់យើង ។ ផ្លូវច្បាប់ អ្នកដែលប្រព្រឹត្ដខុសលើជនរងគ្រោះ ត្រូវតែទទួលទោសតា មផ្លូវច្បាប់ ដូចជាព្រួតគ្នាទៅវាយជំនិងជ:ទឹកទឹក អាស៊ីដលើអ្នកដទៃ នេះបើគេស្ទាប់អ្នកដែលប្រព្រឹត្ដ ត្រូវជាប់ទោសអស់ មួយជីវិត ។ ២-លើ និយាយពីវប្ប:ធម៌ ខ្ញុំរយើងវាមិនល្អ ទេ រឿងយើងនៅ លីវ ទៅទាក់ទងប្ដីរបស់គេ ប៉ុន្ដែ ក៏មិនមែនជារឿងធំដុំដែរព្រោះមានការយល់ព្រមទាំងពីរនាក់ ។ ម្យ៉ាងទៀត អ្នកដែលប្រព្រឹត្ដខុស កំពុងតែមានមុខមាត់ក្នុងសង្គមទៀត ហ៊ានធ្វើអ្វីដែលខ្លួនចង់ធ្វើ ដោយមិនខ្លាចរអាច្បាប់បន្ដិចសោះ ។ បើយើងជាបុរសមិនទៅរកគេ គេក៏មិនទៅរកយើងដែរ លើយមុន នឹងកើតមានព្រឹត្ដិការណ៍នេះ ប្រហែលជាមានរឿងទាស់ទែងរវាងប្ដីប្រពន្ធ មុនទៅហើយ ។

លោក ម្យ៉ែង ឈានណារ៉ាឫទ្ធិ ធ្វើការនៅវិទ្យាស្ថាន សារពើពន្ធកម្ពុជា

រឿងចាក់ទឹកអាស៊ីដ គឺជាទោសព្រហ្ម:ទណ្ឌ យើងអ្នកធ្វើខុស ត្រូវទទួលខុសត្រូវ បើច្បាប់មិនដោះស្រាយទេ វាជាគ្ងំរអាក្រក់ដល់ប្រជាជនខ្មែរ ព្រោះប៉ុន្មានថ្ងៃនេះ ក្រោយពីមានរឿងចាក់ទឹកអាស៊ីដលើរូប កញ្ញា ភាត សារីណា លើយ មានរឿងចាក់ទឹកអាស៊ីដជាច្រើនករណី

ទៀត ដោយមិនបានរាប់ពីរឿងឃាតកម្ម១ ។ ដូច្នេះ យើងត្រូវនាំអ្នកប្រព្រឹត្ដខុសមកសារភាពចំពោះមុខច្បាប់អោយបាន ។ ជាយោបល់របស់ខ្ញុំ នេះគឺជាអំពើឃាតកម្មដ៏ប្រយោលរបស់អ្នកដឹកនាំផ្ទាក់ខ្ពស់ ព្រោះរាល់ថ្ងៃនេះ អ្នកដែលបំរុងធ្វើអាក្រក់កំពុងតែរៀនសូត្រតាមគ្នា ហើយ ច្បាប់ នៅមិនទាន់ចាប់អ្នកទោសនោះមកដាក់ទោស នៅឡើយ ។ ម្យ៉ាងទៀត សូមអោយអង្គការដែលទទួលខុសត្រូវផ្ដែកស្ត្រី ដូចជាមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ មណ្ឌលពតិមានស្ត្រីកម្ពុជា ។ល។ ជួយធ្វើការផ្សព្វផ្សាយបន្ដការអប់រំ អោយកាន់តែខ្លាំងថែមទៀត ចំពោះគ្រួសារណាដែលខិលខូច ដូចជាគ្រួសារដែលមានប្ដី ជាមនុស្សធ្វើបាបប្រពន្ធកូនឬប្រពន្ធ ជាមនុស្សប្រព្រឹត្ដិខុស ។ល។

> **ច្បាប់ដ្ឋមន្ដ្រីឌុញ្ញ ហ្សាក្នា ៤៥ បានចែងថា"...បុរសនិងស្ត្រី មានសិទ្ធិស្មើគ្នា ក្នុងគ្រប់គ្រិសម័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ១ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមបណ្ដូលចិត្ដ ដែលមានចែងក្នុងច្បាប់និងតាមគោលការណ៍ស្មុគ្រគ្រិត្ត ម្ដីមួយ ប្រពន្ធមួយ១**

លោកជ្ជ ម្ហ ណ ឆ ណា ធ្វើការនៅក្រសួងវប្ប:ធម៌ និងទេសចរណ៍

ក្នុងនាមខ្ញុំ ជាអ្នកមានប្ដី ខ្ញុំមិនកាន់ជើងខាងប្រពន្ធណាឡើយ បើស្រីកំណាន់នោះស្ងាត់ស្ងៀម មិនអុកឡុក ប្រហែលជាមិនអីទេ លើយប្រពន្ធដើម ក៏វាជ្រុលពេកដែរ រឿងចាក់ទឹកអាស៊ីដវាសាហាវខ្លាំងណាស់ ។ ហេតុនេះវាខុសទាំងសងខាង ខាងប្រុសក៏អញ្ចឹងដែរ បើបានជាមានស្ត្រីក្រៅពីប្រពន្ធហើយ យើងត្រូវតែចេះអោយតំលៃប្រពន្ធដើមបានខ្ពស់ យើងមិនត្រូវលើកតំកើងប្រពន្ធក្រោយពេកទេ ធ្វើអោយប្រពន្ធដើមមានការតូចចិត្ដ ព្រោះមិនមែនទើបស្រឡាញ់គ្នាតែមួយថ្ងៃឯណា គឺរាប់ឆ្នាំទៅហើយ សរុបមកគឺបុរសជាអ្នកខុស បើយើងមិនទៅរកគេ ក៏គេមិនមករកយើងដែរ ។ ចុងបញ្ចប់ ខ្ញុំសំណូមពរ សូមអោយអំពើឧក្រិដ្ឋកម្មគ្រប់បែបយ៉ាងត្រូវបញ្ចប់ កុំអោយកើតមានតទៅទៀត ។ សូមអោយរដ្ឋាភិបាល ជួយទប់ស្កាត់និងមានវិធានការណ៍ពឹងរឹង ចំពោះជនដែលប្រព្រឹត្ដខុស យកមកផ្ដន្ទាទោសអោយបាន ។

អ្នកស្រី ហ្ម ន ឆ ណា ធ្វើការនៅក្រសួងវប្ប:ធម៌ និងទេសចរណ៍យ៉ន់ឌុកមនាគមន៍

ក្នុងនាមខ្ញុំ ជាអ្នកមានប្ដី ខ្ញុំមិនកាន់ជើងខាងប្រពន្ធណាឡើយ បើស្រីកំណាន់នោះ ស្ងាត់ស្ងៀម មិនអុកឡុក ប្រហែលជាមិនអីទេ លើយប្រពន្ធដើម ក៏វាជ្រុលពេកដែរ រឿងចាក់ទឹកអាស៊ីដវាសាហាវខ្លាំងណាស់ ។ ហេតុនេះវាខុសទាំងសងខាង ខាងប្រុសក៏អញ្ចឹងដែរ បើបានជាមានស្ត្រីក្រៅពីប្រពន្ធហើយ យើងត្រូវតែចេះអោយតំលៃប្រពន្ធដើមបានខ្ពស់ យើងមិនត្រូវលើកតំកើងប្រពន្ធក្រោយពេកទេ ធ្វើអោយប្រពន្ធដើមមានការតូចចិត្ដ ព្រោះមិនមែនទើបស្រឡាញ់គ្នាតែមួយថ្ងៃឯណា គឺរាប់ឆ្នាំទៅហើយ សរុបមកគឺបុរសជាអ្នកខុស បើយើងមិនទៅរកគេ ក៏គេមិនមករកយើងដែរ ។ ចុងបញ្ចប់ ខ្ញុំសំណូមពរ សូមអោយអំពើឧក្រិដ្ឋកម្មគ្រប់បែបយ៉ាងត្រូវបញ្ចប់ កុំអោយកើតមានតទៅទៀត ។ សូមអោយរដ្ឋាភិបាល ជួយទប់ស្កាត់និងមានវិធានការណ៍ពឹងរឹង ចំពោះជនដែលប្រព្រឹត្ដខុស យកមកផ្ដន្ទាទោសអោយបាន ។

អ្នកស្រី សុិម ចាន់យ៉ា

អ្នកស្រី សារ៉ា ឌីថា

អង្គការ CCHDO

ឆ្នាំ២០០០ ក្បែរឆ្នេរសមុទ្រ ខ្មែរ-ថៃ អំពើជួញដូរមនុស្សនិងបន្ទាយពេស្យាចារ កើតឡើងច្រោចច្រាត មិនចាញ់នឹក្ខេត្តភ្នំពេញ ប៉ុន្តែនៅឡើយ។ អង្គការមិនមែនរដ្ឋអាណាបាលមួយចំនួន កំពុងបើកនីតិវិធីនៅទីនោះ ដើម្បីជួយសង្គ្រោះកុមារីនិងយុវតី ដែលត្រូវការជំនួយ ជាពិសេសនាំចរណៃ ក្នុងចំណោមអង្គការទាំងអស់ អង្គការ CCHDO បានបើកមណ្ឌលរបស់ខ្លួននៅភ្នែកខ្ចីមួយលាប់ប្រាំដងៗ

កុំអោយស្ត្រីជនៃរងគ្រោះ ជួបខ្ទប់ទៀត

ស្ទូរម៉ាស៊ីនដេរជាច្រើនគ្រឿងលាន់រ៉ូ ចេញពីផ្ទះឈើប្រក់ប៉ាវ៉ាកេសីមួយសង់ផ្ទាល់ដី។ យុវតីប្រមាណ២០នាក់ កំពុងអង្គុយនៅមុខម៉ាស៊ីនដេរ ១ខ្លួន។ គេទាំងអស់ហាក់ដូចជាយកចិត្តទុកដាក់នឹងការងារនេះណាស់ មិនឆ្ងេចឆ្ងាចងាកឆ្ងេងស្ដាំឡើយ ទ្ចីបើនៅពីមុខផ្ទះនោះ មានមនុស្សម្នាក់ការ។ ខ្លះជាអ្នកវាត់ម្ជុលតួឈរ ១ចាំ ១ អង្គុយ ១ សំរាកកែ ១ ១ ១

CCHDO ORGANIZATION

In Poipet, in the vicinity of the Khmer-Thai border, there is an increase in human abduction, trafficking and brothels, as much and as remarkable as in the royal capital city of Phnom Penh. Some non-governmental organizations were established there with the aim to save girls and women who have escaped from those hells on earth. CCHDO is also one of the organizations which is situated near the roundabout next to the border.

I hope other girls will not experience the same ill-fate as I did

Noisy sounds of many sewing-machines waft through the air, coming from a wooden house with a sheet-iron roof. About twenty young girls are operating their machines skillfully and are in good mood. They all seem to concentrate their attention only on their work even though there are crowds of people in front of the house. Some of them are motor-taxi drivers waiting for their clients and some are sitting for a rest beside some baggage which they have just carried from the Phsar Thai market. Standing here, one can clearly see the light-blue sign with the Angkor Wat towers marking the Khmer-Thai border. Phea Savoeun, a rather thin girl with long hair which was tied at the back, said she was from a commune in Mongkul Borei district, Banteay Meanchey province. She was cheated and sold to a brothel in Poipet for 2,000 baht. She has been here for only a week. She said she detested brothels and would like to appeal to the Royal Government to close down all the brothels so that no girls would have unfortunate lives as she now has, because the brothel owners are very inhuman. They beat the girls (the sex workers they controlled) severely if those girls refuse to have sex with a client. Her ideas and request were then shared by Ms Rong Ry from Siemreap, Ms So Ran from Svay Rieng and Ms Sem Saroeun from Prey Kloth in B.Bang province, who were sewing beside her. These girls are victims of sex trafficking and are provided with both shelter and vocational training and education by CCHDO.

They can also learn literacy, numeracy and sewing

Mr. Chamreun Virak, assistant in the anti-prostitution program, said the organization has two main goals, one of which is aimed at reducing the number of children who are forced to do hard labor and the other is to cut down the number of young girls who suffer from prostitution. Its main aim is to target teenagers. To achieve these two goals, the organization set up two centers, one for children who have suffered from hard labor and another for girls who have suffered from prostitution.

The latter is called Poipet Vocational Training Center, which organizes a course lasting six months for twenty girls. There are two types of training: one is teaching literacy and numeracy to illiterates, and another is teaching sewing skills. To this end, the center organized another course for the illiterates so that they could learn both literacy and sewing. During the course, the participants are provided with food and accommodation, and those with sexually transmitted diseases will be sent to the Medecins Sans Frontière for medical treatment. CCHDO is supported by the UN Center and World Food Program.

Mr Chamroeun Virak went on to say there are more than 30 brothels in Poipet, each of which has six or seven prostitutes. Most of them were cheated into prostitution. In order to save those girls, the organization first requested the local authorities to convene a meeting of all the brothel owners, who are required to release the girls who wish to leave the brothels. Doing this enables the organization to go and fetch the girls without causing any problems once it gets news that there are girls wanting to leave the brothels.

The news can be received from the local police, people living near the brothels or from the clients. There are many more girls who wish to leave, but CCHDO can accept only twenty for each course. Those girls can go to other orga nizations, such as CWCC, for help.

No hope that such the problem can be solved.

Mr. Chamroeun Virak expressed his pleasure at having improved the lives of those girls, training them in sewing skills and treating their sexually transmitted diseases. But he complained that it seemed very difficult for the girls to learn to read as they seemed to suffer from a loss of memory due to being physically tortured when they were in the brothels. Furthermore, when they first arrived at the center, some girls seemed to be grief-stricken and some seemed very bored and wanted to go out for a walk, but the Center Director did not allow them to do this as she was afraid that they might be caught or cheated by the brothel owners again. It took a long time to educate them before they became stable and could pull themselves together. Another difficulty is that the organization cannot afford money to cure diseases other than the STDs because Medecins Sans Frontière agrees to treat only the STDs.

Concerning the crackdown on sex trafficking, Mr. Virak stated no measures had so far been taken by police, except the one previously taken when a brothel owner had beaten a prostitute to death. Then the police arrested and sent the brothel owner to court, but she was later released. Now it has been heard that the District Chief has been thinking of taking action to crack down on the brothels. Mr Virak expressed no hope of tackling this problem. He would like to appeal to the Royal Government to take necessary measures to close down all brothels. In his opinion, he does not want the Government to legalize prostitution as he thinks that it would be even more and more difficult to manage it once it is legalized.

Ms Sim Chanya

សេចក្ដីជូនដំណឹង

ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ សូមជំរាបជូនលោកស្រី នាងកញ្ញា អស់លោកថា យើងខ្ញុំសូមស្វាគមន៍ រាល់ការសុំជាវទស្សនាវដ្ដី ពីសំណាក់អស់លោកអ្នក។ អស់លោកអ្នក អាចអញ្ជើញមកទាក់ទងនៅមជ្ឈមណ្ឌល នៅគ្រប់ពេលម៉ោងធ្វើការ។

ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ មានកំណើតចាប់តាំងពីឆ្នាំ១៩៩៣ គឺប៉ុន្មានខែបន្ទាប់ពីការបោះឆ្នោតលើកទី១។ ទិសដៅរបស់ទស្សនាវដ្ដី គឺផ្សព្វផ្សាយពត៌មានទាំងឡាយអំពីស្ត្រី ក្នុងគោលបំណងលើកស្ទួយស្ថានភាពស្ត្រីខ្មែរ។ ក្នុង១ឆ្នាំ យើងផលិតបាន៨លេខ បោះពុម្ពចំនួនពី២០០០ ទៅ៣០០០ច្បាប់ ក្នុង១លេខ។ ទស្សនាវដ្ដីត្រូវបានចែកចាយទៅគ្រប់ស្ថាប័នរដ្ឋ មានសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ស្ថានទូត បណ្ណាល័យ និស្សិត អង្គការក្រៅរដ្ឋាភិបាល ជួរនារី និងជួរអប់រំ នៅតាមខេត្តនានា និងមួយចំនួនបានផ្ញើទៅបរទេសផងដែរ។

Information

Khmer Women's Voice Centre would like to inform you that we welcome to your purchase of our magazine. You can come and contact us any working hour.

Khmer Womne's Voice magazine have been established since 1993, a few months after the first election. The objective of it is to dessiminate women issue in the aims at promoting women situation. In one year, eight issues are published_2000 or 3000 copies are published in one issue. They are provided to every where such as member of parliament, government, embassy, libraries, students, NGOs, women in provinces and abroad.

ទស្សនៈ

អ្នករក្សាវប្បធម៌ខ្មែរនៅទល់ដែន

ថ្មីៗ បើសៅរ៍ឆ្លាយពីអាជីវកម្ម ហ្វូតដាច់ដាតទល់ដែនខ្មែរ-ថៃ គឺនៅមានស្ត្រីខ្មែរម្លាត់ ត្រាមការជួយឧបត្ថម្ភ ពីអង្គការមិនមែនរដ្ឋាភិបាលមួយកំពុងចិតខំបណ្តុះបណ្តាលសិស្សកុមារស្ថិតក្នុងវប្បធម៌ជាតិខ្លួនដែរ។ នោះ គឺកញ្ញា ស្រីអាន ស្លូតត្រួហ្ចឺតហាត់រយៈពេលជាង ក្មេងម្លាត់។

ហាត់រៀនជ្ជាំ

សំលេងពិណពាទ្យលាន់ឮរាំ ចេញពីក្នុងបន្ទប់ មួយនៃអាគារមួយខ្នង ដែលឋិតនៅទីរួមស្រុកសៀរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ នារីម្នាក់ក្នុងសំលៀកបំពាក់ធម្មតាខោជើងវែង អាវផ្ការ កំពុងឈរវាយ៉ាងបំបូរាណ ខ្មែរយ៉ាងទន់ភ្លន់ ចំកណ្តាលបន្ទប់ ។ នៅពីមុខនាង កូនសិស្សស្រី១ប្រ មាណ៥-៦នាក់ កំពុងអង្គុយមើល ដោយយកចិត្តទុកដាក់ ។ បន្ទាប់មកនារីនោះ ឈប់រាំ ដើរទៅចុចម៉ាញេ សាឡើងវិញ ។ កូនសិស្សស្រី១ ទាំងអស់ ក៏ក្រោកឡើងឈរជាជួរ ហើយចាប់ផ្ដើមរាំ តាមចង្វាក់ភ្លេង ។ នារីដើរពីសិស្សម្នាក់ទៅ សិស្សម្នាក់ កែលំអកាយវិការរបស់សិស្ស ។ នារីនោះ គឺជាអ្នកគ្រូផ្នែករបាំបូរាណ នៃអង្គការ មិនមែនរដ្ឋាភិបាល "គ្រួសារថ្មី" ។ នាងមានឈ្មោះថា ស្រី អាន ។ ក្នុងជន្មាយុ២១ឆ្នាំ ស្រីអានមានសម្ផស្សស្រស់ស្អាត គួរអោយចង់គយគន់ ។ សម្បុរសស្អាតទំនង កូនកាត់ខ្មែរ-ចិន ស្រីអានទុកសក់រ៉ែងអន្លាយតែចងជាប់ខាងក្រោយ ។ នាងមានសាច់ល្មម មិនស្គម តែក៏មិនធាត់ពេកដែរ ។ ម្រាមដៃ ម្រាមជើងខ្លីៗ តែលើកឡើងរាំ កាលណា ទន់ភ្លន់ដូចក្នុងគំនូរ ។ ស្រីអាន បានប្រាប់អោយដឹងថា នាងមកធ្វើការនៅអង្គការ" គ្រួសារ

កញ្ញា ស្រី អាន កំពុងរាំរបាំអោយសិស្សមើល

ថ្មី"នេះ ជិត២ឆ្នាំហើយ ។ របាំបូរាណ ដែលនាងចេះ ហើយកំពុងផ្ដល់ដល់សិស្សក្មេងៗ រាល់ថ្ងៃនេះ មាន២ប្រភេទ គឺរបាំប្រជាប្រិយ និងរបាំបូរាណ ។

នាងរៀបរាប់ថា នាងរៀនរាំតាំងពីអាយុ១៣ឆ្នាំ គឺនៅឆ្នាំ១៩៨៥ នៅជំរំជនភៀសខ្លួន រហូតដល់ជំរំរ៉ាសាយ នៅឆ្នាំ១៩៩៣ ។ គ្រូដែលបង្ក្រៀនពេលនោះ ជាគ្រូធ្លាប់ហាត់រៀននៅសាលាវិចិត្រសិល្ប: ឈ្មោះអ្នកគ្រូពៅ ។ យុវតី បញ្ជាក់ថា មូលហេតុដែលបណ្តាលអោយនាងចូលហាត់រាំ គឺមកពីកាលណោះ នាងនៅជំរំជាមួយម្តាយ ក្រៅពីរៀននៅសាលាចំណេះទូទៅ នាងចំនេះច្រើន ។ ម្យ៉ាងទៀត កាលណាហាត់រៀនគេជួយឧបត្ថម្ភ១ខែ៣០បាត (៣៣ន់

កញ្ញា ស្រី អាន កំពុងបង្ហាត់រាំ

រៀល) ។ មុនដំបូងនាងមិនមានចិត្តស្រលាញ់ប៉ុន្មានទេ ប៉ុន្តែលុះហាត់យូរៗទៅ នាងកាន់តែជាប់ចិត្តឡើងនឹងក្បាច់រាំនេះ ការលំបាកដែលនាងជួបក្នុងពេលហាត់នោះគឺ ការឈឺខ្លួនក្នុងពេលពត់ដៃពត់ជើង កាច់ចង្កេះ កាច់ខ្នង ។ ប៉ុន្តែទោះពិបាកយ៉ាងនេះក៏ដោយ ក៏នាងមិនរួញរា ហើយចាំបានគ្រប់ក្បាច់ទាំងអស់ ។ ដោយនាងរាំបានល្អជាងគេ នាងក៏ក្លាយទៅជាតួឯករាំមុខគេរហូត ។ កញ្ញា ស្រីអាន បង្ហាញនូវទឹកចិត្តសប្បាយរីករាយចំពោះជោគជ័យ ក្នុងការហាត់រៀនរបស់នាង ។ ក្រោយពីហាត់រៀនចេះហើយ កញ្ញា ស្រីអាន បានទៅសំដែងនៅតាមកន្លែងជាច្រើន នៅក្នុងជំរំ និងនៅខេត្តសុរិន្ទ ប្រទេសថៃ ។ ពេលនោះ មានទស្សនិកជនជាខ្មែរនិងបរទេស បានមកទស្សនា ។ ក្រោយពីជំរំរ៉ាសាយមក ស្រីអាន ត្រឡប់មករស់នៅជាមួយម្តាយឯខេត្តបាត់ដំបង ។ តាំងពីនោះមក នាងពុំដែលបានហាត់រៀនរបាំទៀតទេ គ្រាន់តែបានបន្តការសិក្សាចំណេះទូទៅ រហូតដល់ជាប់បាក់ឌុបប៉ុណ្ណោះ ។ យុវតីប្រាប់ថា នាងចង់បន្តការសិក្សានៅមហាវិទ្យាល័យឯក្រុងភ្នំពេញណាស់ ប៉ុន្តែគ្មានបងប្អូនសោះ ដូច្នេះហើយបានជានាងត្រូវផ្ទាកការសិក្សាត្រឹមនេះ ។ គាប់ជួនពេលនោះ អង្គការគ្រួសារថ្មីត្រូវការអ្នករាំ នាងក៏ត្រូវបានមកធ្វើការនៅទីនេះ រហូតដល់បច្ចុប្បន្ន ។ អ្នកស្រី ភូ វណ្ណនី អ្នកទទួលខុសត្រូវ

របាំដែលកញ្ញា ស្រីអាន
កំពុងបង្ហាត់ ចង្ក្រៀន
របាំប្រជាប្រិយ : ត្រឡោក គេន នេសាទ
*ក*ន្ទ្រឹមណ្ណេហ៍ សម្ពន្ធ្ធបក្សី
*របាំបូរាណ : ជ្ជនពរ ភ្ជងនារី ផ្ទ្ធិត ការយឹម នារីជាជ្ជូ ខ្មែ*ររអង្ករ មាន់ សេកសារិកា ទ្ធិវាប្រពៃ
ចុជ្ជរលោ កិយ ទេអ*ំ*ណៅ*ជ*ាបូ* រ*ាណ ម*ណ*ីទ*េ*ខ*ា*ឡ*ា
នាតលេង ទ*ឹ*ក *ស*ុ*វ*ណ្ណ*ម*ច្ឆ*ា ព*្រ*ះ*ច*ន្ទ*ត*ោ*ព ។

នៅសាលាលោនស្បែកអង្គការគ្រួសារថ្មីនិយាយថា ស្ត្រីដែលចេះរបាំបូរាណបែបនេះ ពុំងាយរកបានឡើយ ។ អង្គការគ្រួសារថ្មីបានស្វះស្វែងរកអស់រយៈកន្លះឆ្នាំឯណោះ ទើបបានជួបប្រទះ ។ អ្នកស្រីបន្ថែមទៀតថា ថ្ងៃត្បិតតែស្រីអាន រ៉ាមិនត្រូវខ្ជាតបាន១០០ភាគរយមែន ប៉ុន្តែចេះប៉ុណ្ណោះ ចាត់ទុកថាចេះច្រើន ហើយអាចបណ្តុះបណ្តាល



កញ្ញា ស្រី អាន និងសិស្សរបាំ

ក្មេងៗជំនាន់ក្រោយបាន ។

ត្រូវជាពលរដ្ឋគាំទ្រពេលនាំសិស្សនៅសំដែង

ជារៀងរាល់ថ្ងៃ កញ្ញា ស្រីអាន បង្ហាត់សិស្សដែលមកពីសាលាចំណេះទូទៅ នៅទីរួមខេត្ត ។សិស្សទាំងនោះ គឺជាអ្នកដែលស្រឡាញ់សិល្ប:របាំ ហើយមកហាត់រៀនដោយស្ម័គ្រចិត្ត និងដោយឥតបង់លុយឡើយ ប៉ុន្តែខ្លះក៏មកជាប់ជាអចិន្ត្រៃយ៍ ខ្លះក៏មកមួយដងមួយកាល សិស្សដែលមកជាអចិន្ត្រៃយ៍ មានចំនួនប្រមាណ២០នាក់ ។ សិស្សទាំង២០នាក់នោះ ត្រូវបានទទួលការបង្ហាត់បង្ក្រៀនគ្រប់របាំបូរាណទាំងអស់ ។ ចំណែកអ្នកដែលមិនបានមករាល់ថ្ងៃ នាងបង្ហាត់អោយរាំតែក្បាច់រាំវង់ រាំក្បាច់និងសារ៉ាវ៉ាន់ប៉ុណ្ណោះ ។ ស្រីអាន បញ្ជាក់ថា សិស្សទាំងឡាយ ច្រើនជាកូនអ្នកក្រីក្រ ។ ក្រោយពីហាត់រៀនបាន ៣ខែ សិស្សរបស់នាងអាចចេញទៅសំដែងនៅតាមភូមិជ្ជនប្រជាពលរដ្ឋទស្សនាកំសាន្ត ។ ក្នុង១ខែ ចុះ២ដង ក្នុង២ភូមិ ។ ស្រីអាន បញ្ជាក់ថា ក្នុងពេលសំដែងអង្គការជាអ្នកចេញលុយកាត់ខាអាវអោយ ហើយនាងជាអ្នកស្បៀកពាក់និងផាត់មុខ ។

ការងារខិតខំបណ្តុះបណ្តាលវប្បធម៌ខ្មែរមានតម្លៃណាស់ចំពោះប្រទេសជាតិ ជាពិសេសនៅតំបន់មួយដែលវប្បធម៌បរទេស កំពុងមានឥទ្ធិពលគ្របសង្កត់មកលើ ។ គឺហេតុនេះ បានជាយើងអាចនិយាយបានថា កញ្ញា ស្រី អាន ពិតជានារីខ្មែរម្នាក់ មានតម្លៃសំរាប់សង្គមខ្មែរ ថ្ងៃបើនាងនៅមានការខ្វះខាតខ្លះក៏ដោយ ។ អ្នកស្រី ភូ វណ្ណនី មានប្រសាសន៍ថា នាងពូកែរ៉ាមែន ប៉ុន្តែនាងនៅខ្វះចរិតជាអ្នកដឹកនាំ ខ្វះវិន័យក្នុងការងារ ហើយជួនកាលឆាប់ខឹងផង ។ ប៉ុន្តែ អ្នកស្រី ភូ វណ្ណនី គិតថាថ្ងៃក្រោយទៅចរិតនេះអាចកែលំអបាន ។

កញ្ញា ស្រីអាន បានបង្ហាញយោបល់របស់នាងថា នាងស្តាយណាស់ ដោយកាលមុនហាត់រៀន នាងហាក់ដូចមិនចាប់អារម្មណ៍ លើសិល្ប:របាំសោះ ឥឡូវនេះ នាងពេញចិត្តណាស់ ដោយឃើញថា ការងាររបស់នាងធ្វើអោយវប្បធម៌ខ្មែរមានតម្លៃ ត្រូវបានប្រជាពលរដ្ឋគាំទ្រ ពេលក្រុមសិស្សរបស់នាងទៅសំដែងក្នុងភូមិម្តងៗ ។ នាងមានសំណូមពរ សូមអោយរដ្ឋាភិបាលមេត្តាគាំទ្រដល់សិល្បៈការជាអ្នកសំដែងជាពិសេសសិល្បៈការដែលនៅទីឆ្ងាយដាច់ស្រយាលដូចជាទីនេះជាដើម ហើយសូមអោយលោកឪពុក អ្នកម្តាយទាំងឡាយ មេត្តាយល់ពីតម្លៃវប្បធម៌ជាតិ អនុញ្ញាតអោយកូនហាត់រៀនផង ប្រសិនបើកូន មានចិត្តចង់រៀននោះ ។

អ្នកស្រី សុម ចាន់យ៉ា

រង្វាន់លេខ១ សហស្សវត្សរ៍ថ្មី

អ្នកស្រី យឹម ឌីម៉ូណា បុគ្គលិកមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ និងជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ មានកិត្តិយសទទួលជ័យលាភីលេខ១ ក្នុងចំណោមបេក្ខជន៨៧នាក់ នាពិការាសប្រលងស្វាដៃអក្សរសិល្ប៍ រង្វាន់ "មហោស្រពអន្តរ" រៀបចំឡើងដោយក្រសួងវប្ប៉ធម៌ ដើម្បីអបអរសាទរសហស្សវត្សរ៍ថ្មី ប្រលោមលោកដែលជាប់ជ័យលាភី នេះមានចំណងជើងថា "ផ្លាវីតចុងរដូវ" មានទ២៦៥ទំព័រ សរសេរដៃ និងបានទទួលរង្វាន់ជ័យលាភីនៅថ្ងៃទី១ មករា ឆ្នាំ២០០០ នៅមុខប្រាសាទអន្តរភក្ត ក្នុងពិធីបុណ្យមហោស្រពអន្តរអបអរសាទរសហស្សវត្សរ៍ឆ្នាំ២០០០។ អ្នកស្រីបានសរសេរឿងនេះ អស់រយៈពេលទ២ខែ ក្នុងឆ្នាំ១៩៩៦។

តើអ្នកស្រីមានអារម្មណ៍យ៉ាងណា ក្នុងពេលបានទទួលជ័យលាភីនេះ?

មានអារម្មណ៍រំភើបរីករាយណាស់ ព្រោះនេះជាលើកទី១ហើយ ដែលខ្ញុំទទួលបានជ័យលាភីលេខ១ ។ ម្យ៉ាងទៀត នេះគឺជាមោទនភាពរបស់ខ្ញុំ ក្នុងនាមជាស្ត្រីខ្មែរមួយរូប ព្រោះក្នុងចំណោមអ្នកទទួលជ័យលាភីទាំង៦នាក់ មានស្ត្រីតែម្នាក់ទេ គឺរូបខ្ញុំ នេះឯង ។

អ្នកស្រី យឹម ឌីម៉ូណា ជាប់ជ័យលាភីលេខ១ ផ្នែកប្រលោមលោក ក្នុងពិធីចែកពានរង្វាន់មហោស្រពអង្គរ២000(រូបទី២រាប់ពីខាងស្តាំ)

តើកន្លងមកអ្នកស្រីធ្លាប់បានទទួលជ័យលាភីអ្វីខ្លះ ក្នុងវិស័យអក្សរសិល្ប៍?

កាលពីឆ្នាំ១៩៩៧ខ្ញុំជាប់បានរង្វាន់លួងចិត្តក្នុងការប្រលងមួយឈ្មោះ "រង្វាន់ ៧មករា" រៀបចំដោយសមាគមអ្នកនិពន្ធខ្មែរ ហើយការរៀបចំនេះឧបត្ថម្ភឡើងដោយសម្តេច ប៊ុនសែន ។ នៅឆ្នាំ១៩៩៨ ខ្ញុំជាប់បានរង្វាន់ លេខ៣ ក្នុងការប្រលងអត្ថបទកំណាព្យ ស្តីពីជំងឺអេដស៍ រៀបចំឡើងដោយអង្គការទស្សនៈពិភពលោក (World Vision) ។

ក្រៅពីស្វាដៃទទួលបានជ័យលាភីនេះ តើអ្នកស្រីធ្លាប់បានតិពន្ធអ្វីខ្លះ?

ខ្ញុំធ្លាប់ បានតិពន្ធប្រលោមលោកភាគបាន២រឿង ។ ប្រលោមលោកនោះបានសរសេរនិងចំឡងដោយដៃសំរាប់ជួលអោយគេមើល ក្នុងអំឡុងទសវត្សរ៍៨០ និងដើមទសវត្សរ៍៩០ ។ បន្ទាប់មក ខ្ញុំបានតិពន្ធរឿងប្រលោមលោក២ទៀត តែពុំទាន់បានបញ្ចាប់ ។ ចំពោះអត្ថបទកំណាព្យវិញ ខ្ញុំបានសរសេរអត្ថបទកំណាព្យជាច្រើន សរុបបានប្រមាណជាង១៥០ទំព័រ ។ ក្រៅពីនេះ ខ្ញុំបានតិពន្ធស្បៃវ៉ែកៅរូបភាពអប់រំខ្លីៗ បាន៤រឿងតែម្នាក់ឯង និងធ្វើក្នុងក្រុម បាន១០រឿង ។ ខ្ញុំបានសរសេររឿង សំរាប់ផ្ដាវីដេអូខ្លីបាន៤រឿង សរសេរអត្ថបទដាក់ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ បានប្រមាណ១០អត្ថបទផងដែរ ។

តើអ្វីខ្លះដែលជំរុញអោយអ្នកស្រី ក្លាយទៅជាអ្នកនិពន្ធ?

តាំងពីក្មេងមក ខ្ញុំមានទិស្សយចូលចិត្តអានស្បៃវ៉ែកៅណាស់ ។ ពេលអាន ខ្ញុំចាប់អារម្មណ៍លើរបៀបសរសេរល្អៗរបស់អ្នកនិពន្ធ ហើយក៏ដុះចិត្តចង់សរសេរ ។ នៅក្នុងថ្នាក់ ខ្ញុំតែងទទួលការសរសើរពីគ្រូ ក្នុងការធ្វើតែងសេចក្ដី ។ នៅអាយុ១៦ឆ្នាំ ខ្ញុំចាប់ផ្ដើមនិពន្ធបានរឿងមួយ ។

បច្ចុប្បន្ននេះ តើអ្នកស្រីមានគោលបំណងដូចម្តេចខ្លះ?

ខ្ញុំចង់ធ្វើអោយខ្លួនខ្ញុំមានកិត្តិយសល្បីល្បាញ ដើម្បីមានលទ្ធភាពផ្សព្វផ្សាយសំនេររបស់ខ្ញុំទៅក្នុងសង្គម ។ ខ្ញុំគិតថា សំនេររបស់ខ្ញុំ ដែលភាគច្រើន ច្រើនជាការអប់រំនឹងជួយរួមចំណែកក្នុងការដាស់តឿនណែនាំមនុស្សក្នុងសង្គមខ្មែរយើងសព្វថ្ងៃ ដែលកំពុងតែមានការខ្វះចន្លោះជាច្រើន ។ ខ្ញុំគិតថា បើខ្ញុំគ្មានកេរ្តិ៍ឈ្មោះទេ ក៏គ្មានអ្នកណាគេចាប់អារម្មណ៍ចង់អានស្នាដៃខ្ញុំដែរ ។

ក្នុងពេលអនាគត តើអ្នកស្រីមានគំរោងយ៉ាងណា?

អ្នកស្រី យឹម ឌីម៉ូណា

អ្នកស្រី យឹម ឌីម៉ូណា

ឆ្នាំកំណើត :	*១៩៥៧*
ទីកន្លែងកំណើត:	*សង្កាត់លេខ៥ក្រុងភ្នំពេញ*
ឪពុក :	*យឹម រស្មី (ស្លាប់) អគ្គលេខាធិការអង្គនៃយុវជនរាជសម្ព័ន្ធនិយមខ្មែរ*
ម្តាយ :	*ព្រាប ចន្ធី (ស្លាប់) មេផ្ទះ*
បងប្អូន :	*កូនទី២ ក្នុងចំណោមបងប្អូន៩នាក់*
ប្ដី :	*ម៉ម ស៊ីផាន់ កងទព័ធ្វើការនៅក្រសួងការពារជាតិ ផ្នែកសំភារៈបរិក្ខា*
រៀបការ :	*១៩៨១*
កូន :	*៣នាក់ (ស្រី១ ប្រុស២)*
ការសិក្សា:	*ថ្នាក់ទី២ទំនើបជាតិ(១៩៧៤-១៩៧៥)*
ការងារ :	*១៩៧៩-៨០ ប្រធានស្ថិតិស្រុកស្អាងខេត្តកណ្ដាល*
	១៩៨០-៨១បុគ្គលិកស្ថិតិផ្នែការខេត្តកណ្ដាល
	១៩៨២-១៩៩៥ រកស៊ីលក់ដូរ
	១៩៩៥-១៩៩៨ សមាជិកសមាគមអ្នកនិពន្ធខ្មែរ
	១៩៩៨-បច្ចុប្បន្ន បុគ្គលិកផ្នែកកម្មវិធីផ្សព្វផ្សាយរបស់ មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ

ខ្ញុំនឹងបន្ដសរសេរទៀត ទាំងប្រលោមលោក ទាំងកំណាព្យ ដើម្បីទុកអប់រំនិងទុកជាស្នាដៃ អោយក្មេងជំនាន់ក្រោយ ។ ខ្ញុំមានបំណងចង់បកប្រែរឿងខ្ញុំ ជាភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយទៅក្រៅប្រទេស ។

តើក្នុងការងារនេះ អ្នកស្រីជួបការលំបាកនិងការងាយស្រួលអ្វីខ្លះ?

ការលំបាកទី១ គឺខ្ញុំពុំមានលទ្ធភាពបោះពុម្ពស្នាដៃខ្ញុំបានដោយគ្មានថវិកា ម្យ៉ាងទៀត ដោយបច្ចុប្បន្ននេះ សង្គមខ្មែរពុំសូវអោយតម្លៃទៅលើការនិពន្ធទេ ។ ការលំបាកទី២ គឺខ្ញុំពុំសូវចេះភាសាបរទេស ធ្វើអោយខ្ញុំពុំមានលទ្ធភាពអានអត្ថបទណា ក្រៅពីអត្ថបទជាភាសាខ្មែរ ហើយក៏ពិបាកក្នុងការបកស្រាយគំនិតខ្ញុំ ឬរឿងខ្ញុំ ជូនជនបរទេសយល់ ប៉ុន្តែខ្ញុំមានការងាយស្រួលមួយ គឺក្នុងគ្រួសារ ប្ដីខ្ញុំគាំទ្រការងារខ្ញុំ ហើយជួនកាលគាត់ថែមទាំងជួយចំលងអោយទៀតផង ។ ក្រៅពីនោះ អ្នកដែលស្គាល់ខ្ញុំ គេគាំទ្រស្នាដៃខ្ញុំថែមទៀត ។

តើអ្នកស្រីមានសំណូមពរអ្វីខ្លះ?

ខ្ញុំសូមអោយអ្នកនិពន្ធទាំងអស់ មេត្តាគិតគូរក្នុងការសរសេររបស់ខ្លួន ធ្វើយ៉ាងណាកុំអោយ មានឥទ្ធិពលអាក្រក់ដល់អ្នកអាន ជាពិសេស យុវជនខ្មែរ ព្រោះសំនេរនីមួយ១ តែងតែមានឥទ្ធិពលដល់អ្នកអាន ។ ក្រៅពីនោះ ខ្ញុំសូមអោយរដ្ឋាភិបាលនិងមហាជនទាំងអស់ ជួយគាំទ្រវិស័យអក្សរសាស្ត្រជាតិយើង អោយបានល្អប្រពៃជាងនេះ ព្រោះបើវិប្បធម៌អក្សរសាស្ត្ររលំ ជាតិនឹងរលាយ ។

អ្នកស្រី ស៊ីម ចាន់យ៉ា

ពត៌មាន

លើកទឹកចិត្ត ស្ត្រី អោយក្លាយជាអ្នកដឹកនាំ

ថ្ងៃទី១៩ ខែវិច្ឆិកា ១៩៩៩ នៅសាលាមធ្យមសិក្សាគរុកោសល្យមតេយ្យ ម្ជឫម មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ បានប្រារព្ធធ្វើសិក្ខាសាលាមួយស្ដីពីយេនឌ័រ មគ្គុទ្ទេសភាព និងលទ្ធិប្រជាធិបតេយ្យ ដោយមានអ្នកចូលរួម១១០នាក់ មកពីអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិក មន្ត្រីរាជការ មកពីខេត្តកណ្ដាល កំពង់ស្ពឺនិងភ្នំពេញ។ បុគ្គលិកមន្ត្រីរាជការទាំងនោះ ត្រូវបានជ្រើសរើសតែពីក្រសួង៣ប៉ុណ្ណោះ គឺក្រសួងអប់រំ សុខាភិបាល និងយុត្តិធម៌។ ព្រោះក្រសួងទាំង៣នេះ គឺជាគន្លឹះ ជាសារវន្ត ដើម្បីផ្ដល់ឱកាសដល់ស្ត្រីអោយមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន។ សិក្ខាសាលានេះ បានទទួលការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល ដោយលោកជំទាវ ឃីម ចំរើន អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី អញ្ជើញជាប្រធានគណៈអធិបតី នៅក្នុងពិធីបើកសិក្ខាសាលា និងឯកឧត្ដម សុខ អាន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ព្រមទាំងលោកជំទាវ អញ្ជើញចូលរួមក្នុងពិធីបិទសិក្ខាសាលា។

សិក្ខាសាលាវគ្គផ្សាយលទ្ធផលស្រាវជ្រាវពីយេនឌ័រ មគ្គុទ្ទេសភាព និងលទ្ធិប្រជាធិបតេយ្យ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នៅសាលាមធ្យមសិក្សាគរុកោសល្យមតេយ្យម្ជឫម

លោកស្រីកុយ វេត នាយិកាប្រតិបត្ដិនៃមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ បានមានប្រសាសន៍ថា គោលបំណងនៃអង្គសិក្ខាសាលាគឺដើម្បីផ្ទាស់ប្ដូរយោបល់ និងបទពិសោធន៍ សំណូមពរ ព្រមទាំងស្វះស្វែងរកនូវយុទ្ធវិធីថ្មីៗ ដើម្បីលើកជូនរាជរដ្ឋាភិបាល អោយជួយបង្កជាលក្ខណៈដល់ស្ត្រីក្នុងការចូលកាន់តួនាទីជាអ្នកដឹកនាំនៅក្នុងសង្គម។

ក្នុងឱកាសនោះឯកឧត្ដម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈ: រដ្ឋមន្ត្រី បានមានប្រសាសន៍ថា អ្វីដែលយើងបានឃើញជាក់ស្ដែង នៅក្នុងបច្ចុប្បន្ននេះ ស្ត្រីគឺមានសមត្ថភាព និងលក្ខណៈសម្បត្ដិគ្រប់គ្រាន់ ក្នុងការចូលរួមប្រឡូកក្នុងសង្គមនយោបាយ លើយឈានទៅកាន់តំណែងនិងតួនាទីយ៉ាងសំខាន់ៗ នៅក្នុងអំណាចនីតិបញ្ញត្ដិ អំណាចនីតិប្រតិបត្ដិនិងអំណាចតុលាការ។ ឯកឧត្ដមទេសរដ្ឋមន្ត្រីបានបន្ដទៀតថារាជរដ្ឋាភិបាល និងបន្ដរកគ្រប់យុទ្ធវិធី ដើម្បីលើកស្ទួយសិទ្ធិនារីអោយបានសមស្របជានារីខ្មែរ នាសហស្សវត្សរ៍ថ្មី ខាងមុខនេះ។ ឯកឧត្ដម សុខ អាន បានបន្ដទៀតថា នៅក្នុងសម័យអង្គរ រចនាសម្ព័ន្ធសង្គមខ្មែរ គឺសង្គមមាតាធិបតេយ្យ ដែលមានតាំងពីជំនាន់នគរភ្នំមកម្ល៉េះ ដូច្នេះ ទស្សនៈយេនឌ័រនេះ គឺមានតាំងពីយូរយារណាស់ មកហើយ។

ក្រោយពីការពិភាក្សាគ្នារួចមក អង្គសិក្ខាសាលាទាំងមូល បានឯកភាពគ្នាលើដំណោះស្រាយដូចតទៅ:

- សំណូមពរចំពោះ រាជរដ្ឋាភិបាលអោយបង្កើតអន្ដរាសិកដ្ឋាន សំរាប់បណ្ដុះបណ្ដាលស្ត្រីនៅឧត្ដមសិក្សា

-សំណូមពរអោយមានគោលនយោបាយប្រើកូតា ដើម្បីលើកទឹកចិត្ដស្ត្រីអោយក្លាយទៅជាអ្នកដឹកនាំថ្នាក់កណ្ដាលសមស្រប តាមប្រសាសន៍ឯកឧត្ដម សុខ អានដែលបានលើកឡើងថា "រាជរដ្ឋាភិបាលនឹងបន្ដរកនូវគ្រប់វិធី ដើម្បីលើកស្ទួយសិទ្ធិនារី អោយបានសមស្របជានារីខ្មែរ នាសហស្សវត្សរ៍ថ្មី ខាងមុខនេះ"។ ការប្រើប្រាស់កូតានេះ ជាការចាំបាច់ នៅពេលដែលការយល់ដឹងពីបញ្ហាយេនឌ័រ មិនទាន់ផុលផុស។

-បំផុសស្ត្រីអោយមានជំនឿទៅលើស្ត្រីគ្នាឯង។

Encouraging Women To Become Leaders

On November 19,1999, the Khmer Women's Voice Center organized a workshop on gender, leadership and democracy at the Central pre-school teacher-training school with the participation of 110 people from various NGOs and from the provinces of Kandal, Kg. Speu and P.Penh city. Those participants were selected from only the three ministries such as the ministry of education, the ministry of public health and the ministry of Justice as they are the fundamental institutions to render women a chance to be sufficiently capable of exercing their rights. The workshop drew the attention from the royal government with the presence of H.E Khim Cham roeun,undersecretary of state for women's and vetaran's affairs,who came to chair the opening ceremony and with the presence of H.E Sok An, minister of state of the council of ministers and his madam, who came to chair the closing ceremony.

Ms Koy Veth, KWVC's exe cutive director, said the workshop was aimed to exchange ideas, opinions and experiences and to search for new more strategies to be submitted to the royal government to help provide favorable conditions to women in assuming their role of leadership in society.

H.E Sok An and his Madam at the closing ceremony of one Day Dissemination workshop on Gender, Leadership and Democracy at Pre-school Teacher Training Center

On that occassion, H.E Sok An said what we have virtuallly seen at present is that women are adaquately qualified in engaging in political society and will assume important positions and roles in both legislative, executive and judicial powers. H.E Sok An went on to say that the royal government would continue to seek every strategy in order to improve women's rights to an acceptable extent to turn them into good khmer women for the new millennium. He further maintained in the Angkorian time, the structure of khmer society was the one which had existed since the Norkor Phnom period, so this view of gender existed for a very long time.

After discussions, the participants agreed on the following points:

-Request the royal government to set up a dormitory to train women at the higher educational levels.

-Request the royal government to apply the policy of using quota to encourage women to become a middle level leadership in comformity with H.E Sok An's speech that "the royal government will continue to seek ways and means to improve women's rights in order to turn them into good khmer women in the new millennium." The use of this quota is necessary when the understanding of gender is not active yet.

-Encourage women to have mutual trust among themselves.

សូមធ្វើគោលនយោបាយមួយពិសេសសំរាប់ស្ត្រី

សិក្ខាសាលាស្ដីពីយេនឌ័រ មគ្គុទ្ទេសភាព និងលទ្ធិប្រជាធិបតេយ្យ
កាលពីថ្ងៃទី១ ដល់ថ្ងៃទី៥ធ្នូ ឆ្នាំ១៩៩៩ នៅមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ

វគ្គ"បណ្ដុះបណ្ដាលគ្រូផ្សព្វផ្សាយបន្ត" មួយបានបើកឡើងដោយមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរនៅទីស្នាក់ការរបស់មជ្ឈមណ្ឌលរយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី៥ ធ្នូ ១៩៩៩ ស្ដីពីយេនឌ័រ មគ្គុទ្ទេសភាព និងលទ្ធិ ប្រជាធិបតេយ្យ។ សិក្ខា កាមចំនួន១៥រូប មកពីក្រសួងអប់រំ សុខាភិបាល យុត្ដិធម៌ និងមន្ទីរ អប់រំ សុខាភិបាល និងយុត្ដិធម៌ខេត្ដកណ្ដាល កំពង់ស្ពឺ ភ្នំពេញ បានចូលរួម។ គោលបំណង នៃវគ្គបណ្ដុះបណ្ដាលនេះ គឺដើម្បីដោះស្រាយឧបសគ្គដែល រាំងស្ទះមិនអោយស្ត្រីចូលកាន់តួនាទី ជាអ្នកដឹកនាំថ្នាក់កណ្ដាលបាន។

សិក្ខាសាលាស្ដីពីយេនឌ័រ មគ្គុទ្ទេសភាព និងលទ្ធិប្រជាធិបតេយ្យ
កាលពីថ្ងៃទី១ ដល់ថ្ងៃទី៥ធ្នូ ឆ្នាំ១៩៩៩ នៅមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ

នៅចុងបញ្ចប់នៃវគ្គ សិក្ខាកាមទាំងអស់ មានសំណូមពរដូចតទៅ :

១-សូមអោយមានការផ្សព្វផ្សាយ បញ្ជ្រាបបញ្ហាយេនឌ័រ តាមគ្រប់រូបភាព

២-សូមអោយរដ្ឋាភិបាលធ្វើគោលនយោបាយមួយ ពិសេសសំរាប់បណ្ដុះបណ្ដាលស្ត្រី និងជំរុញស្ត្រីអោយមានតួនាទីដឹកនាំ។

៣-ក្នុងរាល់ការបោះឆ្នោត សូមអោយប្រធានគណបក្សទាំងអស់ យកចិត្ដទុកដាក់ជំរុញស្ត្រី អោយឈរឈ្មោះជាបេក្ខជន

៤-សូមអោយ មានការអប់រំអោយស្ត្រី មានការទុកចិត្ដលើខ្លួនឯងនិងរំដោះខ្លួនពីការគាបសង្កត់របស់សង្គម

៥-សូមអោយ ស្ត្រីជំរុញស្ត្រីគ្នាឯងអោយឈានឡើង

៦-សូមអោយស្ត្រីមានសេចក្ដីក្លាហាន ក្នុងការចូលរួមមតិក្នុងទីសាធារណៈអោយបានច្រើន។

ក្នុងខែមករា និងកុម្ភៈ ឆ្នាំ២០០០នេះ សិក្ខាកាមទាំងអស់នឹង ចុះទៅធ្វើការផ្សព្វផ្សាយ



ស្ដីពីសង្គម

ការចោលសំរាម

បច្ចុប្បន្ននេះ បញ្ហាចោលសំរាមក្លាយទៅជាបញ្ហាមួយធ្ងន់ធ្ងរ ជាពិសេសនៅរាជធានីភ្នំពេញ។ ភាពឥតសណ្ដាប់ធ្នាប់នៃការចោលសំរាម មិនត្រឹមតែធ្វើអោយខូចបរិស្ថាន បំផ្លាញអនាម័យ និងបំផ្លាញសោភ័ណភាពប៉ុណ្ណោះទេ តែបង្ហាញអោយឃើញនូវភាពខ្វះសុជីវធម៌របស់លោកអ្នក។

នៅក្នុងគេហដ្ឋាន

គួរមានធុងសំរាមនៅក្នុងផ្ទះ។ បើផ្ទះធំច្រើនជាន់គួរដាក់ធុងសំរាមអោយបានច្រើនកន្លែង ធ្វើយ៉ាងណាអោយមានការងាយស្រួលក្នុងការចោលសំរាម។ ទោះបីខ្មែរយើង ជាពិសេសនៅជនបទ ពុំមានទម្លាប់ដាក់ធុងសំរាមតាមផ្ទះក៏ដោយ ក៏លោកអ្នកគួរចាប់ផ្ដើមអោយមានទម្លាប់នេះ តាំងពីឥឡូវ។ ប្រសិនបើ លោកអ្នកមិនចង់ចំណាយលុយ ទិញធុងសំរាមនៅទីផ្សារទេ លោកអ្នកអាចប្រើរបស់ដែលមានសណ្ឋានដូចធុងសំរាមក៏បានដែរ ដូចជាកន្ត្រោកញ្ជើ ឬធុងជាដើម។ អ្នកនៅក្នុងផ្ទះទាំងអស់ ត្រូវធ្វើយ៉ាងណាអោយមានទំលាប់មួយក្នុងខ្លួន គឺអ្វីៗទាំងអស់ត្រូវចោលក្នុងធុងសំរាម មិនត្រូវចោលលើក្ដារ លើឥដ្ឋ ឬបោះចោលតាមបង្អួចទៅ លើដីឡើយ។ អ្វីៗទាំងនោះ រាប់តាំងពីក្រដាស សំបកនំ សំបកផ្លែឈើជាដើម។ កាលណាធុងសំរាមជិតពេញ ត្រូវយកទៅចោល មិនត្រូវទុកអោយហូរហៀរ ឬធ្លាក់ក្លិនស្អុយជូរផ្ទួមឡើយ។ សំរាមទាំងនោះ គួរដឹកដឹកប់ ឬជុះតចោល ឬទុកអោយគេមកដឹកជញ្ជូន។

នៅក្នុងទីសាធារណៈ

នៅតាមទីសាធារណៈ ដូចជាតាមផ្លូវ សួនច្បារ ចំណតឡាន វាលយន្ដហោះ សាលារៀន ហាង ផ្សារ រោងកុន រោងល្ខោន ក្នុងឡានឈ្នួល។ល។ អជ្ញាធរដែនដី គួរដាក់អោយមានធុងសំរាម។ ធុងសំរាមទាំងនោះ ត្រូវមានអ្នកយកទៅចោលជាប្រចាំ។ ប្រជាពលរដ្ឋម្នាក់ៗត្រូវមានស្មារតីភ្ញាក់រលឹក យកសំរាមទៅចោលក្នុងធុងសំរាមគ្រប់ពេលវេលា។ ប្រសិនបើពេលដែលអ្នកបកសំបកពោត ឬសំបកស្ពរគ្រាប់ ឬចង់ចោលដបទឹកបរិសុទ្ធ នៅចំពេលដែលគ្មានធុងសំរាមក្បែរ លោកអ្នកគួរតែដាក់ក្នុងស្បោង ឬដាក់ក្នុងកាបូបសិន ទំរាំដល់ពេលឃើញធុងសំរាម សឹមអ្នកបោះចោល។ អ្នកមិនត្រូវបោះចោលលើដី លើឥដ្ឋ ឬលើសួនច្បារ ដោយសំអាងថា មិនមានធុងសំរាមក្បែរនោះឡើយ។ មាតាបិតា រៀមច្បងឬចាស់ទុំ គួរតែណែនាំកូនចៅអោយចេះចោលសំរាមជានិច្ច។ បើអ្នកចោលសំរាមស្រេចនឹងចិត្ដ អ្នកត្រូវគេសំគាល់ថា ជាអ្នកគ្មានសុជីវធម៌ក្នុងការរស់នៅក្នុងសង្គម ព្រោះធ្វើអោយរំខានដល់អ្នកជិតខែក្បែរអ្នក និងដល់សង្គមទាំងមូល។

អ្នកស្រី សុិម ចាន់យ៉ា

សុជីវធម៌ក្នុងពេលសិក្សា

បច្ចុប្បន្ននេះ ការបាត់បង់សុជីវធម៌នៅក្នុងថ្នាក់រៀន ក៏ដូចជានៅក្នុងសាលារៀន កំពុងតែជាបញ្ហាមួយដែលរុញច្រានកុមារ កុមារី ឬយុវជនខ្មែរអោយធ្លាក់ចុះទៅក្នុងភាពស្ពឹកស្ពន់ និងភាពអនាធិបតេយ្យគ្រប់ប៉ែបយ៉ាង។ ដើម្បីជាគន្លឹះជួយដល់ប្អូន១យុវសិស្សទាំងអស់អោយអនុវត្ដនូវសុជីវធម៌ ដែលជាគ្រឹះនាំមកនូវសេចក្ដីថ្លៃថ្នូរ ការចេះដឹងនិងចិត្ដចរិយាទន់ភ្លន់ ប្រកបដោយសតិសម្ប ជញ្ញៈ មនសិការខ្ពស់ ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរសូមចូលរួមចំណែកជួយផ្ដល់នូវការចេះដឹង១ចំនួនដែលទាក់ទងទៅនឹងសុជីវធម៌ក្នុងពេលសិក្សា។

ក្នុងថ្នាក់រៀនគប្បីស្បៀមស្ងាត់ស្ងាប់ គ្រូពន្យល់ មិនត្រូវដំជែកឡូឡា ឬបញ្ចេញសូរស័ព្ទនាំអោយរំខានដល់ការសិក្សារបស់អ្នកដទៃ។ មិនត្រូវប្រើ ពាក្យសំដីអសុរស ទៅកាន់គ្នានឹងគ្នានាំអោយ ក្លាយទៅជាទម្លាប់មួយមិនល្អ ទាល់តែសោះ។ ការខុសឆ្គងបន្ដិចបន្ដួច ដោយអចេតនាទៅលើមិត្ដភក្ដិ ឬគ្រូត្រូវចេះប្រើវាចាសុំទោសជាកិច្ចគួរសម ចៀសវាងការធ្វើបីមិនដឹងខ្លួន ជាហេតុនាំអោយ អ្នកដែលយើងប៉ះពាល់ទៅលើនោះ មានក្ដីអាក់អន់ស្រពន់ចិត្ដ ចាត់ទុកថាយើងមាក់ងាយគេ។ ក្នុងនាមជាសិស្ស យើងមិនត្រូវ ប្រកាន់ឬកពាអោយខ្ពស់ ឬ ក៏ស្មើនឹងគ្រូឡើយ។ មិនគួរគប្បី យកករបស់ប្រើប្រាស់ក្នុងការសិក្សា កម្មសិទ្ធិអ្នកដទៃ ដោយឥតមានការគួរសមសុំខ្ចីជាមុននោះទេ។ ការលេងសើចរវាងមិត្ដភក្ដិ ក៏មិនត្រូវអោយហួស ឬតដល់ចូលក្នុងន័យ មាក់ងាយនោះដែរ។ ត្រូវចេះជួយសំអាតថ្នាក់រៀនរួមគ្នា មិនត្រូវបោះចោលសំរាមតែពីសតែពាសដោយអាងថាពុំមែនជាវេន ដែលខ្លួនត្រូវសំអាតថ្នាក់នោះឡើយ។ ត្រូវចេះប្រើអាកប្បកិរិយា ឱនលំទោន និងសំពះសួរ ឬសំពះលា ចំពោះអ្នកគ្រូ លោកគ្រូ។ ចង់និយាយសួរនាំអ្វីទៅកាន់មិត្ដដទៃ ត្រូវហៅឈ្មោះ មិនត្រូវសួរទទេ ទេ ឧទាហរណ៍ "សុំ ទោស...មិ ត្ដ...បង...ឬ ប្អូ ន...។ល។" ការអនុវត្ដនូវសុជីវធម៌ខាងលើនេះ នាំអោយបួនយុវសិស្សទាំងអស់ អាចក្លាយទៅជាសិស្សគំរូ ដែលនាំមកនូវភាពរុងរឿងថ្លៃថ្នូរ នៅក្នុងសង្គម។

អ្នកស្រី យ៉ីម ឌីម៉ូល្លា

ម្ហូបចំណី

ប្រហុកតែងគ្រឿង

គ្រឿងផ្សំ : ប្រហុកសាច់ស្បៃមរាប កន្លះគីឡូ សាច់ជ្រូកជាប់ខ្លាញ់ ៨ខាំ ត្រីឆ្អើរត្រីកែសឬកន្លាងហាយ៣ខាំ ក្រសាំងឆ្អៀលរួចប្រហែល ៣ខាំ ម្ទេសឆ្អើរ ១ខាំ សណ្ដែកដី ៣ខាំ ខ្លាញ់ជ្រូក គល់ស្លឹកគ្រៃ រមៀត ស្លឹកក្រូចសើច ខ្ទឹមស ក្រហម ស្ករស។ បន្ថែមអន្ទក់ ចេកខ្ចី ត្រប់ស្រួយ ស្ពៃក្តោប ពពាយ ត្រសក់ ការ៉ុត ។

វិធីធ្វើ: គល់ស្លឹកគ្រៃបុកឱ្យម៉ដ្ឋជាមួយរមៀត ខ្ទឹមស ក្រហម រួចទុកមួយឡែក។ សណ្ដែកដីលីងបកសំបករួចបុកឱ្យម៉ដ្ឋ។ ស្លឹកក្រូចសើចហាន់ជាសរសៃផ្ទារ១ ម្ទេសឆ្អើរត្រាំទឹកហូតសរសៃហើយចោល រួចចិញ្ច្រាំបុកឱ្យម៉ដ្ឋទុកមួយឡែក។ ប្រហុកចិញ្ច្រាំឱ្យម៉ដ្ឋ ចូកដាក់ចាន ។ សាច់ជ្រូកចិញ្ច្រាំឱ្យម៉ដ្ឋដាក់ចានមួយផ្សេង។ ត្រីឆ្អើរបេះយកសាច់មកបុកឱ្យម៉ដ្ឋ។

ដាក់ខ្ទះដាំចាក់ខ្លាញ់ចូលបន្តិច យកសាច់ជ្រូកចិញ្ច្រាំមកឆាឱ្យឆ្អិន រួចដាក់ប្រហុកចិញ្ច្រាំហើយ មកឆាជាមួយឱ្យសព្វ បន្ទាប់មកត្រូវយកក្រសាំងឆ្អៀលរួចឆាជាមួយគ្នា ។ លួមថាចូលគ្នាសព្វហើយត្រូវយកត្រីឆ្អើរបុករួច គ្រឿងបុកហើយ ស្លឹកក្រូចសើចហាន់ហើយសណ្ដែកដីបុករួចមកចាក់បញ្ចូលគ្នាក្នុងខ្ទះដាក់ប៊ីចេង និងស្ករសចូលឆាឱ្យសព្វភ្លក់មើលឱ្យលួមតាមចូលចិត្ត ។ ប្រហុកតែងគ្រឿងនេះបរិភោគផ្ទាប់ជាមួយអន្ទក់ខាងលើ ហើយអាចទុកបានយូរថែមទៀតផង ។

អ្នកស្រី យីម ឌីម៉ូណា

ទំបត់ស្លឹកស្រស់

គ្រឿងផ្សំ : សណ្ដែកបាយ ស្ករស ម្សៅសណ្ដែក ។

វិធីធ្វើ : ត្រាំសណ្ដែកបាយលាងសំបកចេញអោយស្អាត ហើយយកទៅដាំដូចបាយអោយឆ្អិន រួចកិនអោយម៉ដ្ឋហើយសួនជាដុំមូលអោយធំល្មម។ ស្លឹកចេកត្រូវបែកអោយធំ ហើយចៀរអោយមូល ម្សៅសណ្ដែកត្រូវលាយទឹកផ្កាម្ទីះ ច្របល់នឹងស្ករអោយរាវបន្តិច ហើយចាក់ទឹកដាក់ខ្ទះលើភ្លើងកូរអោយខាប់ឆ្អិនម្សៅឡើងរលើបល្ម សឹមដាក់ចុះយកស្លឹកចេកសំរាប់ខ្ចប់នោះកេរជាកន្ទោងចុងស្រួច ហើយដួសដាក់ក្នុងកន្ទោង យកស្នូលសួនទុកនោះដាក់ក្នុងម្សៅ ហើយបត់ចុងស្លឹកចេកសងខាងចូលមករៀបដាក់ចានជាការស្រេច ។

ជំណាប់សំបកក្រូចផ្ទុង

វិធីធ្វើ : យកសំបកក្រូចផ្ទុងមកចិតសំបកក្រៅអោយអស់ ទុកតែសំបកស១ទើបកាត់ធ្វើជារាងមូល១ ដាក់ត្រាំទឹកកំបោរចំនួន១០នាទី សឹមស្រង់ពួតអោយអស់ទឹក ទើបយកទៅស្រុសទឹកក្តៅ ។ យកខ្ទះស្ពាន់ដាក់ស្ករដាំអោយឡើងស្ងិតបន្តិច សឹមយកសំបកក្រូចផ្ទុងមកពួតអោយស្ងួតមកដាក់រម្ងាស់អោយខ្ទះទឹកល្ពជាការស្រេច ។

ដកស្រង់ចេញពីស្បៃវភៅវិជ្ជាធ្វើម្ហូបរបស់អ្នកគ្រូ ឡុង សារ៉ីន

ជួបជាមួយអ្នកអានចំណុំ



ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ មានក្តីរីករាយ ស្វាគមន៍រាល់លិខិតរបស់ មិត្តអ្នកអានក្នុងការផ្ញើសំណួរពររីករាយទស្សនាវដ្ដី ជួយមានយោបល់ដោះស្រាយបញ្ហា ដែលកំពុងតែធ្វើអោយជីវិត មានវិបត្តិ។

ខ្ញុំ ឈ្មោះ គ ល រៀនៅវិទ្យាល័យ តាខ្មៅ សូមជំរាបមកទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ នូវរឿងរ៉ាវជីវិតទ័លច្រករបស់នាងខ្ញុំ នាបច្ចុប្បន្ន និងដើម្បីសុំជាយោបល់មួយចំនួនគ្រាន់បំភ្លឺជាផ្លូវសំរាប់ដោះស្រាយនូវបញ្ហាដែលកើតមានក្នុងជីវិតរបស់នាងខ្ញុំផ្ទាល់នេះផង ។

នាងខ្ញុំមានម្តាយដែលជាស្ត្រីមេម៉ាយម្នាក់ រកស៊ីចិញ្ចឹមកូនរហូតដល់ទៅ៥នាក់ ដែលសុទ្ធតែនៅលីវទាំងអស់ ។ ក្នុងចំណោមបងប្អូនទាំង៥នាក់នោះ មានប្រុសទាំងអស់៤នាក់ លើយនាងខ្ញុំគឺជាកូនទី២ក្នុងគ្រួសារ ។ ដូច្នេះទ្ធិត្យិតតែនាងខ្ញុំពុំមែនជារៀមច្បងបង្អស់ក៏ដោយ ក៏នាងខ្ញុំនៅតែទទួលបន្ទុកការងារក្នុងនាមជារៀមច្បងគេដែរ ។ ដោយហេតុទាំងអស់នេះហើយទើបនាងខ្ញុំ មានការខ្វាយខ្វល់ចិត្តយ៉ាងខ្លាំង មិនដឹងជាគិតទៅផ្លូវណា ឬមួយក៏នាងខ្ញុំត្រូវបញ្ឈប់ការសិក្សាតែត្រឹមនេះ ហើយទៅជួយម្តាយក្នុងការរកស៊ីអោយបានពេញដៃពេញជើង? ឬមួយក៏ត្រូវទ្រាំត្រដាបត្រដួសដូច្នេះទៅដើម្បីសិក្សាបន្ត? តែបើទ្រាំដូច្នេះ នាងខ្ញុំដូចជាមិនដាច់ចិត្តទាល់តែសោះព្រោះ ដូចជាអាត្មានិយមខ្លាំងពេក ដោយមិនអាណិតដល់កំលាំងម្តាយ ។ ជាចៃដន្យថែមទៀតនោះ ការលំបាកក្នុងគ្រួសារនាងខ្ញុំនេះ កើតមានឡើងនៅក្នុងឆ្នាំដែលនាងខ្ញុំកំពុងត្រៀមប្រឡងយកបាក់ឌុបតែម្តង ហេតុនេះសូមទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ ដែលជាទស្សនាវដ្ដីមួយយកចិត្តទុកដាក់រាល់បញ្ហាសុខទុក្ខរបស់ស្ត្រី មេត្តាជួយស្រាយបំភ្លឺ ឬបង្ហាញផ្លូវនាងខ្ញុំដោយអនុគ្រោះ ។

ចម្លើយ:

ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ សូមអរគុណដល់ប្អូនស្រី គ ល ដែលបានផ្ដល់ទំនុកចិត្តមកលើទស្សនាវដ្ដី ក្នុងការជួយដោះស្រាយបំភ្លឺនូវបញ្ហាទ័លច្រករបស់ប្អូនដែលលើកឡើងនេះ ។ ក្នុងនោះផងដែរ ទស្សនាវដ្ដីក៏មានសេចក្ដីអាណិតចំពោះរូបប្អូនស្រីយ៉ាងខ្លាំង ដោយប្អូនជាកូនស្រីម្នាក់ដែលចេះគិតគូរបែងចែកអំពីបញ្ហាលំបាកក្នុងគ្រួសារ និងចេះស្រលាញ់ការសិក្សា ។ ទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ សូមជំរាបប្អូនដោយស្មោះថា គ្មានអ្វីដែលមានតម្លៃស្មើនឹងចំណេះវិជ្ជានោះទេ ប៉ុន្តែទន្ទឹមនឹងនោះ ក៏ត្រូវធ្វើអោយជីវិតមានជីវភាពរស់នៅសមរម្យផងដែរ ។ ប្អូនធ្លាប់អានទស្សនាវដ្ដីនេះ ប្អូនបានយល់ហើយថា ទស្សនាវដ្ដីមានទស្សនៈ និងគោលបំណងចង់អភិវឌ្ឍន៍ស្ត្រីខ្មែរអោយក្លាយទៅជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ ដើម្បីរួមចំណែកក្នុងការកសាងសង្គមជាតិ ចង់អោយស្ត្រីមានការជឿជាក់លើខ្លួនឯង មានសេចក្ដីក្លាហានប្រឈមរាល់បញ្ហារាំងស្ទះ ហើយនិងចេះតស៊ូក្នុងជីវិតទៀតផង ។ ទស្សនាវដ្ដីមិនចង់ឃើញយុវតីខ្មែរណាមួយ បោះបង់ការសិក្សាពាក់កណ្ដាលទីព្រោះតែឧបសគ្គនោះឡើយ ។ ទស្សនាវដ្ដីលើកឡើងនេះ មិនមែនមានន័យថា ត្រូវតែអោបយកការសិក្សា ហើយទុកអោយក្រពេះក្រៀមស្វិតនោះទេ ។ ដូច្នេះប្អូនអាចជ្រើសរើសយកផ្លូវមួយក្នុងចំណោមផ្លូវពីរដូចតទៅ :

១-ស៊ូទ្រាំត្រដាបត្រដួសមួយរយៈតូចទៀត ដើម្បីចាប់យកសញ្ញាប័ត្របាក់ឌុបអោយបានសិន ដែលជាការងាយស្រួលបន្តការសិក្សាបានទៀតនៅពេលណាដែលប្អូនមានឱកាស ។

២-ប្រសិនបើប្អូនគិតថា គ្មានវិធីជ្រើសរើសក្រៅពីបញ្ឈប់ការសិក្សាទេនោះ ចូរប្អូនព្យាយាមរកឱកាសរៀននៅម៉ោងចន្លោះណាមួយក្រៅពីការជួយរកស៊ីរបស់ម្តាយ ដើម្បីបង្កើនចំណេះដឹងរបស់ប្អូន ទាំងផ្នែកភាសាបរទេស កុំព្យូទ័រ ឬចំណេះដឹងទូទៅ បន្ថែមទៀត ងាយស្រួលប្អូនរកការងារចិញ្ចឹមជីវិតទៅអនាគត ហើយក៏អាចជាស្ពានជួយចំលងគ្រួសារ ប្អូនអោយចាកផុតពីភាពលំបាក ទៅថ្ងៃមុខទៀតផង ។

សូមមិត្តអ្នកអាន សរសេរលិខិតមកមជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ តាមអាសយដ្ឋាន: ផ្ទះលេខ៥៤ ផ្លូវ៤៧០ សង្កាត់ទួលទំពូង១ខ័ណ្ឌចំការមន ភ្នំពេញ ប្រអប់សំបុត្រលេខ៥៤០ ទូរស័ព្ទនិងទូរសារលេខ (០២៣) ២១ ២៣ ៥២ ។

ជួបជាមួយចិត្តអ្នកអាន



ឯកឧត្តម ម៉ៅ សម្បត្ដិ អនុរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម

ខ្ញុំមានកិត្ដិយសផ្ដល់ជូន នូវចំណាប់អារម្មណ៍លើខ្លឹមសារនៃទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ ដែលបានផ្ញើជូនខ្ញុំជារៀងរាល់លេខដូចខាងក្រោម:

អត្ថបទទាំងឡាយដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីកន្លងមកនេះប្រកបដោយអត្ថន័យនិងអត្ថរសធំធេងណាស់ព្រោះថាគោលបំណងជាចំបងគឺផ្ដល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ អោយយល់ដឹងអំពីបញ្ហាស្ត្រីនិងយល់ច្បាស់ថា" ស្ត្រីជាមាតានៃពិភពលោកដ៏ពិតប្រាកដ" ។ ពិសេសអប់រំស្ត្រីអោយមានកិត្ដិយស មានសេចក្ដីថ្លៃថ្នូរ មានភាពអង់អាចក្លាហាន ស្វែងយល់អំពីសិទ្ធិរបស់ខ្លួន ហើយខិតខំប្រឹងប្រែងធ្វើយ៉ាងណាអោយខ្លួនមានសមត្ថភាពគ្រប់គ្រាន់ មានបញ្ញាញាណភ្លឺថ្លា និងប្រកបមុខរបរអ្វីៗមិនចាញ់បុរសឡើយ ។ ព្រមជាមួយនេះ ជួយដល់នារីខ្មែរអោយមានក្ដីសង្ឃឹមក្នុងជីវិតរបស់ខ្លួន ដើម្បីរួមចំណែកកសាងនិងអភិវឌ្ឍន៍សង្គមកម្ពុជាអោយរីកចំរើនដូចអារ្យប្រទេសនានា ពិសេសដូចបណ្ដាប្រទេសក្នុងតំបន់ ។

ទន្ទឹមនឹងនេះខ្ញុំសូមជូនមតិខ្លះ ក្នុងគោលបំណងជួយលើកស្ទួយនារីខ្មែរនាពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ។ ក្នុងសម័យបុព្វកាលប្រវត្ដិសាស្ត្រកម្ពុជា បានបញ្ជាក់ច្បាស់លាស់ណាស់ថា នារីខ្មែរមានសេចក្ដីថ្លៃថ្នូរ អង់អាចក្លាហាន នារីខ្មែរជាកវី ជាវិស្វករជាមេទ័ព ។ល ។ ឧទាហរណ៍ : ក្នុងសម័យកោះគោកធ្លក ព្រះនាងលីវយี ហៅសោមាជាអ្នកគ្រប់គ្រងប្រទេស ។ ដូច្នេះសូមលោកស្រី លើកយកប្រវត្ដិស្នាដៃនារីខ្មែរក្នុងសម័យនគរភ្នំ សម័យបន្ទាយស្រី សម័យលង្វែក ។ល ។ ចុះក្នុងទស្សនាវដ្ដី ដើម្បីជួយឧបត្ថម្ភស្ត្រី លើផ្នែកស្នារតី ជួយបំផុសនិង ជំរុញស្ត្រីអោយមានចំណេះដឹងទូលំទូលាយ បង្កើនជំនឿជឿជាក់លើខ្លួនឯង ។ ព្រោះថា ស្ត្រីខ្មែរត្រូវបានបាត់បង់ស្នារតីស្នើរទាំងស្រុង ក្រោយពីបានឆ្លងកាត់របបប្រល័យពូជ សាសន៍ ៣ឆ្នាំ ៨ខែ ២០ថ្ងៃកន្លងមកនេះ ។

ក្រោយពីបានអានទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ ចំពោះខ្លួនខ្ញុំផ្ទាល់គឺយល់កាន់តែច្បាស់ពីស្ត្រីយើងបច្ចុប្បន្ន ដែលបានលើកស្ទួយទាំងសមត្ថភាពនិងជីវភាពរស់នៅ ដោយមិនអង់ចាំតែបុរសរកស៊ីចិញ្ចឹមដូចស្ត្រីពីសម័យមុនទេ រហូតមាន ការងារខ្លះដែលស្ត្រីធ្វើបាន បុរសធ្វើមិនបានក៏មានដែរ ។

អ្នកស្រី ឆុង សាន ប្រធានកិច្ចការនារីក្រុមហ៊ុនមជ្ឈមណ្ឌលឃ្លីនិក(បន្ទាយមានជ័យ)

ក្រោយពីបានអាននិងតាមដានទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរមក នាងខ្ញុំមានការពេញចិត្ដយ៉ាងខ្លាំងចំពោះអត្ថរូប អត្ថរសនិងអត្ថន័យដ៏មានខ្លឹមសារនិងសារៈប្រយោជន៍ នៃពត៌មានបានចុះក្នុងទស្សនាវដ្ដីនេះ ។

ក្នុងនាមនាងខ្ញុំជាស្ត្រីខ្មែរ នាងខ្ញុំយល់ឃើញថា ពត៌មានភាគច្រើនដែលទាក់ទងជាមួយស្ត្រី ហើយដែលទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរបានចុះផ្សាយ អាចជាស្នារតីមួយចំនួន ដែលពុំទាន់បានអភិវឌ្ឍន៍ខ្លួនអោយចេះប្រឹងប្រែងមិនអស់សង្ឃឹមក្នុងជីវិត ។ ទន្ទឹមនឹងនេះដែរ ទស្សនាវដ្ដីនេះពិតជាតំណាងអោយសម្លេងស្ត្រីខ្មែរទូទាំងប្រទេស ដែលកំពុងទាមទារនិងជំរុញអោយសង្គម មានការយកចិត្ដទុកដាក់ចំពោះស្ត្រី ដែលកំពុងទទួលភាពអយុត្ដិធម៌និងរងគ្រោះគ្រប់បែបយ៉ាង ។ ទ្ធីត្បិតតែទស្សនាវដ្ដីនេះ មិនទាន់មានសោភ័ណអោយសក្ដិសម និងការចង់បានក្នុងទីផ្សារក៏ដោយ ក៏នាងខ្ញុំយល់ថា មានអត្ថន័យយ៉ាងសំខាន់បំផុតក្នុងការជួយសង្គម និងផ្ដល់ផលប្រយោជន៍ដល់ស្ត្រីយើង ប្រសើរជាងទស្សនាវដ្ដីមួយចំនួនខ្លះ ដែលប្រើសោភ័ណភាពទាក់ទាញ ក៏ប៉ុន្ដែក្នុងន័យបំពុលវប្ផធម៌សង្គម ។ នាងខ្ញុំសូមសំណូមពរ សូមអោយអង្គការសម្លេងស្ត្រីខ្មែរ បោះពុម្ពទស្សនាវដ្ដីនេះ ចែកជូនដល់ស្ត្រីនៅតាមជនបទដាច់ស្រយាល ដើម្បីជាជំនួយដល់ស្នារតីស្ត្រីទាំងនោះ បានយល់ដឹងនិងមានវិធានការណ៍ទប់ស្កាត់ រាល់អំពើទាំងឡាយណាដែលក្បៀបសង្គត់ និងអយុត្ដិធម៌ដល់ស្ត្រីយើង ។ ជាពិសេស នាងខ្ញុំនឹងខិតខំយកការចេះដឹងពីទស្សនាវដ្ដីទាំងប៉ុន្ដានទៅផ្សព្ធផ្សាយបន្ដ ដល់បងប្អូនស្ត្រីនៅតំបន់ឆ្ងាយ ១ ដែលមិនបានទទួលមានការយល់ដឹងក្នុងសង្គម តាមរយៈការប្រជុំនិងសិក្ខាសាលា ។

ចំណែកយោបល់ផ្ដាំផ្ញើសម្លេងស្ត្រីខ្មែរ

មជ្ឈមណ្ឌលយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះ **ឯកឧត្តម ម៉ៅ សម្បត្ដិ** និង **អ្នកស្រី ឆុង សាន** ដែលបានយកចិត្ដទុកដាក់ក្នុងការតាមដានអានទស្សនាវដ្ដីសម្លេងស្ត្រីខ្មែរ ហើយយល់ច្បាស់ព្រមទាំងផ្ដល់យោបល់ល្អ១ មានការយល់ដឹងខ្ពស់ពីថែមទាំងយកការយល់ដឹងទាំងនេះ ទៅផ្សព្ធផ្សាយបន្ដ ។ យោបល់និង សំណូមពរ របស់លោកអ្នកយើងខ្ញុំនឹងយកមកត្រិះរិះ ហើយបំពេញទៅតាមលទ្ធភាព

អ្នកស្រី ស៊ិម ចាន់យ៉ា

អាវ៉ៃ

ព្រោះតែតម្លៃ

ថ្ងៃមួយម្ដាយរបស់ប្រុញបានអោយលុយទៅប្រុញ ដើម្បីជូនបងប្រុសទាំងបីមកកាត់សក់ ។ មកដល់មុខតូបកាត់សក់ ប្រុញក៏និយាយទៅកាន់ជាងកាត់សក់

ប្រុញ : ជាង កាត់សក់អោយក្មេងមួយនាក់ យកថ្លៃប៉ុន្ដាន?

ជាងកាត់សក់: មួយក្បាល យកថ្លៃ១០០០រៀល

ប្រុញ : ម៉ែចក៏យកថ្លៃម្ល៉េះ យកថ្លៃតែ៥០០រៀលទៅបានហើយ

ជាងកាត់សក់មិនមាត់ មិនក អ្វីទាំងអស់ ។ មួយស្របក់ក្រោយមក ប្រុញក៏ត្រឡប់មកយកបងប្អូនវិញ ស្រាប់តែភ្ញាក់ព្រើតដោយឃើញសក់ក្បាលបងប្អូនទាំងបី កាត់តែមួយចំហៀង នៅសល់មួយចំហៀងទៀតមិនទាន់កាត់ ប្រុញក្ដៅចិត្ដយ៉ាងខ្លាំង

ប្រុញ : ជាង ! ហេតុអីក៏កាត់សក់បងប្អូនប្រុសខ្ញុំតែមួយចំហៀងដូច្នេះ

ជាងកាត់សក់: តម្លៃមួយក្បាល ១០០០រៀល ដូច្នេះមួយចំហៀង ត្រូវនឹងថ្លៃ៥០០រៀលហើយ

ប្រុញ : អុញ !!!

អ្នកស្រី សារ៉ា ន៉ីតា

ចង់ល្ងី

ថ្ងៃនេះពូម៉ុក និងមីងម៉ក់គាត់ចំណាយលុយជាច្រើន គាត់រីករាយនឹងប្រជុំកូនទាំងអស់ដើម្បីសំណេះសំណាលគ្នាលេង

ពូម៉ុក : ថ្ងៃនេះពុកសប្បាយចិត្ដណាស់ ពុកចង់ដឹងពីយោបល់កូន១ៗថាតើកូនចំឡើងពួកកូនចង់ធ្វើការងារ ដើម្បីឱ្យមានកេរ្ដិ៍ឈ្មោះល្បីល្បាញនឹងគេ

កូនម៉ាច : កូនចង់ក្លាយជាអ្នកចំរៀងតាមវិទ្យុនិងទូរទស្សន៍ដ៏ល្បីម្នាក់ដែលទូរទស្សនិកជនបានឃើញនិងសរសើរ

កូនម៉ាង : ទេ! កូនចង់ក្លាយជាតារាវីដេអូពូកែវាយទាត់ធាក់រូបសង្ហារនារីតាមស្រឡាញ់ ហើយអ្នកមើលសរសើរ

កូនម៉ៅ : ខ្ញុំចង់ធ្វើជាតួកំប្លែង បើចង់ឱ្យរឿងល្អមើលទាល់តែមានអ្នកកំប្លែង

កូនមុាំ : ខ្ញុំចង់ធ្វើប្រធានាធិបតីបំរើជាតិឱ្យបានល្អ ប្រវត្ដិសាស្ត្រនឹងចារឹកឈ្មោះកូន

មីងម៉ក់ : អីយ៉ាមិនធម្មតាទេកូនម៉ែ សូមឱ្យបំណងកូនបានសំរេច ។ ចុះកូនពោវិញយ៉ាងណាដែរ?

អាម៉ង្ដវ៉ាតូចជាងគេ ហើយក៏កាចជាងគេដែរអ្វីដែលវ៉ាចង់និយាយគឺគេនិយាយអស់ទៅហើយ

វ៉ាអង្គុយធ្វើក្អែកម៉ក់១

វ៉ាចង់ធ្វើប្រធានាធិបតីដែរព្រោះវ៉ាឃើញគេដង្ហែរស្រមៅស្រមកតែឥឡូវអាម៉ាំវ៉ាយកទៅហើយ ។

ពូម៉ក់ : យ៉ាងម៉េចទៅហើយកូនពៅ?

កូនម៉ង្ដ : បាទខ្ញុំចង់ធ្វើជាអ្នកប្រឆាំងនឹងប្រធានាធិបតី នៅពេលនោះខ្ញុំនឹងបានល្បីដូចជាបងម៉ាំអញ្ចឹងណាពុក

ពូម៉ុក មីងម៉ក់និងកូនទាំងបួន: អុញ!!!.....នេះបានពិតជាអាម៉ង្ដមែន

អ្នកស្រី យ៉ីម ន៉ីម៉ាណ

ការងារលេខ២

បច្ចុប្បន្ននេះវិស័យកែចនិពន្ធអក្សរសិល្ប៍ដែលជាភ្នាក់ងារសំខាន់មួយ សំរាប់បំពេញអោយបញ្ជាធម៌អក្សរសាស្ត្រជាតិ ត្រូវបានស្ត្រីកំពុងតែដណ្ដើមយកលើសលំដាប់ចំណាត់ថ្នាក់ គួរជានិមោនន:។ ក្នុងនោះ កញ្ញា ហ៊ី គឹមស៊ាប ដែលមានមុខងារជាគ្រូនៅគរុកោសល្យវិក្រិតការខេត្តបាត់ដំបង ក៏ត្រូវបានទទួលចំណាត់ថ្នាក់លេខ២ ពានរង្វាន់អក្សរសិល្ប៍ ព្រះសីហនុរាជលើកទី៣ ផ្ទៃកត់ណាញ្ញទ្ធអាំងប្រទេសជាដែរ សំរាប់ឆ្នាំ ១៩៩៩នេះ។

នេះជាលើកទីពីរហើយដែលរូបនាងមានកិត្តិយស

ក្នុងទឹកមុខស្រស់ស្រាយ សំលៀកបំពាក់អាវប៉ាក់ពណ៌ពងមាន់ គូបផ្ទាំ នឹងសំពត់ផ្ការមួងបត់ពណ៌ខ្ចាញ់ក្តាម កញ្ញា ហ៊ី គឹមស៊ាប កំពុងតែឱ្យពានរង្វាន់មួយធ្វើអំពីប្រាក់ ឈរពីមុខម៉ាស៊ីនថតរូប ដែលត្រៀមចុចយករូបនាងរួចជាស្រេច។ នាងបាននិយាយដោយរំភើបរីករាយថា នេះជាលើកទី១ហើយដែលរូបនាងមានកិត្តិយសត្រូវបាន ជាប់ចំណាត់



កញ្ញា ហ៊ី គឹមស៊ាប Miss Hi Kimseab

ថ្នាក់លេខ២ ផ្ទៃកកំណាព្យ ពានរង្វាន់អក្សរសិល្ប៍ព្រះសីហនុរាជលើកទី៣ទូទាំងប្រទេស សំរាប់ឆ្នាំ១៩៩៩ ដែលរៀបចំឡើងដោយសមាគមអ្នកនិពន្ធខ្មែរ ក្រោមព្រះកិច្ចឧបត្ថម្ភនៃព្រះរាជទ្រព្យផ្ទាល់ របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងដំណើរឈានទៅមុខបណ្ដើរ កញ្ញា ហ៊ី គឹមស៊ាប បានបន្ដពោលថា "ទ្វីត្បិតតែខ្ញុំពុំទាន់ឈាន រហូតដល់ចំណាត់ថ្នាក់លេខ១ ក៏ដោយចុះ តែខ្ញុំនៅតែសប្បាយចិត្ត ព្រោះខ្ញុំគិតថា នៅក្នុងចំណោមបេក្ខជនបុរសជាច្រើន ខ្ញុំអាចមានសមត្ថភាពចូលរួមប្រកួតប្រជែង លើយនិងទទួលជោគជ័យ ដូចបំណងប្រាថ្នា។

ក្រុមគ្រួសាររបស់នាងជួយជាអ្នកជួយណែនាំ

កញ្ញា ហ៊ី គឹមស៊ាប គឺជាអតីតយុវសិស្សវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង។ ក្រោយពីនាងប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សារួចមក នាងបានបន្ដការសិក្សានៅមហាវិទ្យាល័យអក្សរសាស្ត្រ រហូតដល់ចប់បរិញ្ញាប័ត្រ។ នាងក៏បានបន្ដសិក្សានៅមហាវិទ្យាល័យគរុកោសល្យ រហូតបញ្ចប់ដោយជោគជ័យបន្ថែមទៀត។ បច្ចុប្បន្ននេះ នាងជាគ្រូនៅសាលាគរុកោសល្យ និងវិក្រិត្យការខេត្តបាត់ដំបង។ កញ្ញា ហ៊ី គឹមស៊ាប បានរៀបរាប់បន្ថែមទៀតថា "កាលពីនៅសិក្សា ជីវិតរបស់នាងពោរពេញទៅដោយភាពលំបាក និងតស៊ូអំណត់ជាទីបំផុត ពីព្រោះគ្រួសាររបស់នាង ពុំមែនជាអ្នកធូរធារនោះឡើយ។ កញ្ញា ហ៊ី គឹមស៊ាប មានបងបួនទាំងអស់ ៤នាក់ ប្រុស២នាក់ ស្រី២នាក់ ហើយរូបនាងផ្ទាល់គឺជាកូនពៅក្នុងគ្រួសារ ដែលមានតែម្ដាយមេម៉ាយនិងបងស្រីក្រមុំម្នាក់ រកទទួលទានដោយធ្វើនំអាកោរលក់ចិញ្ចឹមគ្រួសារ។ នាងបានបញ្ជាក់យ៉ាងច្បាស់ថា ដោយការលះបង់ខ្ពស់របស់បងស្រីនាង ទាំងការសុខចិត្ត ទ្រាំលាត់មិនបានសិក្សា និងមិនយកស្វាមី ដើម្បីផ្ដល់ឱ្យកាសក្នុងការថែរក្សានិងផ្ដត់ផ្គង់ពួកនាង ទើបលទ្ធផលនៃការលះបង់នេះ បានជួយរុញច្រានបងប្រុសទាំង២របស់នាង និងរូប នាងផ្ទាល់ រហូតដល់ត្រើយនៃការសិក្សា។ ទន្ទឹមនឹងនេះផងដែរ នាងក៏បានបញ្ជាក់បន្ថែម

ទៀតថា នាងមិនភ្លេចគុណអង្គការASPECA ឡើយ បើកុំតែបានអង្គការនេះជួយឧបត្ថម្ភចិញ្ចឹមរូបនាងក្នុងនាមជាកុមារកំព្រា ព្រមទាំងរកឪពុកធម៌ ម្ដាយធម៌ សំរាប់ជួយផ្ដត់ផ្ដង់នាងក្នុងការសិក្សារវាង២ឆ្នាំចុងក្រោយនេះទេ ប្រហែលជានាង ក៏នឹងត្រូវជួបការលំបាកធ្ងន់ធ្ងរ ជាងនេះពុំខានឡើយ។

ក្នុងន័យនេះផងដែរ អ្នកមីង លាន ហួយ អាយុ៦៤ឆ្នាំ ត្រូវជាម្ដាយរបស់នាង ផ្ទាល់ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា អ្នកមីងសូមអគុណដល់អង្គការ ASPECA និងលោក CHOLLE MICHELE ព្រមទាំងលោកស្រី CLAUDIEN ជាជនជាតិបារាំងរស់នៅទីក្រុង Paris ហើយដែលត្រូវជាម្ដាយឪពុកចិញ្ចឹមរបស់កូនស្រីអ្នកមីងផងដែរ បើកុំតែបានអង្គការនេះ និងលោកទាំងពីរជួយទេ ម្ល៉េះសមប្រហែលជាអ្នកមីង ត្រូវជួបប្រទះនឹងការលំបាកក្នុងជីវភាព រហូតដល់លក់ផ្ទះដើម្បីផ្ដត់ផ្គង់កូនមិនខានឡើយ។ បានជាអ្នកមីងនិយាយដូច្នេះ ព្រោះកន្លងមកអ្នកមីងតែងគិតរួចជាស្រេចថា បើសិនជាកាល:ទេស:វាបង្ខំខ្លាំង អ្នកមីងនឹងចំណាយទីលំនៅផ្ទាល់ដើម្បីជួយរុញច្រានកូនអោយដល់ត្រើយនៃការសិក្សា ពីព្រោះអ្នកមីងមិនអាចអោយកូនរៀន ពាក់កណ្ដាលហើយ ឈប់នោះទេ។ សព្វថ្ងៃនេះ កូនទាំងបី ក៏មានការងារធ្វើអស់ហើយដូចជា យុវជន អ៊ាប ប៊ុនលឿន ជាវេជ្ជបណ្ឌិតនៅខេត្តសៀមរាប យុវជន ហ ី គឹមហ្ស៊ីង ជាមន្ដ្រីបំពើការនៅទីស្ដី ការគណៈរដ្ឋមន្ដ្រី និងកញ្ញា ហ ី គឹមស៊ាប ដែលជាកូនស្រីពៅ ក៏ចេញធ្វើគ្រូទៀតផង។



កញ្ញា ហ ី គឹមស៊ាបនិងក្រុមគ្រួសារ Miss Hi Kimseab and Her Family

នាងចូលចិត្តការសៀវភៅ និងព្យាយាមរៀនសូត្រ

កញ្ញា ហ ី គឹមស៊ាប បាននិយាយថា មុននឹងនាងក្លាយជាអ្នកនិពន្ធដូច្នេះ គឺនាងបានឆ្លងកាត់ការសិក្សានិពន្ធកំណាព្យពីលោកសាស្ត្រាចារ្យ ជ័យ ចាប ដែលបច្ចុប្បន្នមានតួនាទីជាឯកឧត្ដមអនុរដ្ឋលេខាធិការនៃក្រសួងអប់រំយុវជន និងកីឡា។ នាងបានឆ្លងកាត់ការសិក្សាវគ្គវិក្រិត្យការតែងនិពន្ធ ពីសមាគមអ្នកនិពន្ធខ្មែរ ដែលមានលោកគ្រូ យូបូ លោក ជាសយ លោក ខ្យ ីវ កុសល លោក ឆយ យ ីហ ីង លោកស្រ ីខ្ជួត ធ ីតា ឯកឧត្ដម យ ក់ គុណ លោក រ ?ា សំអាត លោក រ ?ៃន សុន ជាគ្រូ និងរៀមច្បងជួយពន្យល់ណែនាំ ព្រមទាំងបានស្គាល់នូវបទពិសោធន៍ផ្ទាល់របស់លោក អ ?ុន សុខហ ីង ក្នុងពេលសន្ទនាគ្នា។ គូបផ្ទាំពីនេះផងដែរ នាងចូលចិត្តអានសៀវភៅសិល្ប:តែងកំណាព្យ របស់ លោក ពេជ្រ ទ ?ុ?ារ ?ិល និងសៀវភៅកំណាព្យរបស់ក្រសួងអប់រំទៀតផង។ នាងបានបញ្ជាក់ក្នុងនោះផងដែរថា ការអានសៀវភៅច្រើន ជាជំនួយជួយរុញច្រានឲ្យនាង អោយក្លាយទៅជាអ្នកនិពន្ធម្នាក់ ក្នុងពេលបច្ចុប្បន្ន។ នាងបានបន្ដទៀតថា កន្លងមកនាងបាននិពន្ធកំរងកំណាព្យ១ ដែលមានចំណងជើងថា "អតីតកាលជួរចត់" មកដាក់ប្រលងនៅសមាគមអ្នកនិពន្ធខ្មែរដែរ តែមិនមានសំណាងបានជាប់ចំណាត់ថ្នាក់ឡើយ ទើបតែលើកនេះទេ ដែលនាងបានទទួលជោគជ័យពិតប្រាកដ។ កញ្ញា ហ ី គឹមស៊ាប បានបញ្ជាក់យ៉ាងច្បាស់ លាស់ថា មូលហេតុទាំងអស់ខាងលើនេះ គូបផ្ទាំនឹងបទពិសោធន៍ផ្ទាល់ពោរពេញទៅដោយការលឺ ចាប់និងតស៊ូនៅក្នុងឆាកជីវិត បានធ្វើ អោយនាងក្លាយទៅជាអ្នកនិពន្ធម្នាក់ នាសម័យថ្ងៃនេះ។ នាងបាននិយាយទៀតថា ក្នុងនាមជាអ្នកនិពន្ធស្ត្រីវ័យក្មេងម្នាក់ នាងនឹងខិតខំធ្វើប្រឱ?ីតយ៉ាងណា ដើម្បីអោយស្នាដៃនាងកាន់តែល្អនិងសុក្រិត ព្រមទាំងមានខ្ជឹម

សារជាប្រយោជន៍អប់រំដល់សង្គម ទៅវិតផង។

កញ្ញា សេង សំណាង អាយុ២៥ឆ្នាំ ជាគ្រូនៅវិទ្យាល័យតាំងក្រសាំង ខេត្តកំពង់ធំ ហើយត្រូវជាមិត្តរួមជំនាន់របស់នាង បាននិយាយថា"គីម ស៊ាប មានចរិតសុភាពស្រគត់ស្រគំ ចូលចិត្តរាប់អានមិត្តភក្ដិ ជាទូទៅ ហើយមានការតស៊ូព្យាយាមរៀនសូត្រណាស់" ទោះបីជាដូច្នេះក៏ដោយ ក៏កញ្ញា ហ៊ី គីមស៊ាប នៅតែយល់ថា ខ្លួននាងនៅមិនទាន់មានចំណេះដឹងគ្រប់គ្រាន់ នៅឡើយទេ។

ព្រោះតែលើកស្ទួយអក្សរសិល្ប៍ និងវប្ប្ធម៌ជាតិ

កញ្ញា ហ៊ី គីមស៊ាប បាននិយាយថា ចំនួនបេក្ខជនប្រឡងផ្ដែកកំណាព្យនេះ ទាំងអស់៧២នាក់ ទាំងរូបនាងខ្ញុំ។ ការដាក់ស្នាដៃប្រលងនេះ ព្រោះតែនាងចង់ជួយលើកស្ទួយអក្សរសិល្ប៍ជាតិនិងវប្ប្ធម៌ជាតិ អោយបានរីកចំរើនផុលផុសឡើងវិញ រួមចំណែកជួយកាត់បន្ថយឥទ្ធិពលអារ្យធម៌និងវប្ប្ធម៌បរទេស ១ចំនួន ដែលពុំសមស្របនិងកំពុងតែសាបព្រោះឥទ្ធិពល និងបំពុលមកលើយុវជនខ្មែរនាសម័យនេះ។ ទន្ទឹមនឹងនេះ ផងដែរ នាងចង់លើកអំពីបញ្ហាស្ថានភាព ស្ត្រីខ្មែរ ដែលកំពុងធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការជួយដូរផ្លូវភេទ និងការបោកប្រាស់យកមកលក់ ធ្វើអោយជីវិតយុវនារីខ្មែរ១ចំនួននោះ ត្រូវជួបនឹងវិបត្ដិ ព្រមទាំងគ្រោះថ្នាក់ឥតឈប់ឈរ និងចង់បង្ហាញដល់សង្គម ដើម្បីជាបទពិសោធន៍ក្នុងជីវិតសំរាប់កូនខ្មែរ ត្រូវតែប្រយ័ត្ន និងឈ្យៀសវាង។ រឿងដែលនាងដាក់ប្រលងមានចំណងជើងថា "វាសនាបុណ្ណរងគ្រោះ" គឺជារឿងពិតរបស់នារីម្នាក់ ដែលត្រូវគេយកមកលក់ដូចសត្ត ហើយក៏នាងបាននិពន្ធផ្ដែប្រឌិតគួបផ្សំខ្លះ នឹងដើម្បីអោយខ្សែរឿងល្អមើលនិងមានទីបញ្ចប់ ។ រឿងដែលនាងនិពន្ធនេះ មានចំនួន១២៦ទំព័រ ហើយប្រើតែពាក្យកាព្យ (កាកគតិ) មួយបទគត់ រហូតដល់ចប់ ។ នាងក៏មានសំណូមពរដល់សង្គមទាំងមូល ក៏ដូចជារដ្ឋាភិបាលផងដែរ សូមអោយយកចិត្ដទុកដាក់ អោយបានខ្លាំងចំពោះបញ្ហា "ចាប់ពង្រត់និងជួញដូរផ្លូវភេទ" ហើយចាត់វិធានការណ៍ ជួយទប់ស្កាត់អោយបានផុលផុស ដើម្បីជួយស្តារស្ថានភាពនារីខ្មែរ អោយប្រសើរឡើងវិញផង។

អ្ន្ដកស្រី យ៉ីម ន៉ីម៉ូ្ណ

The Second-ranked Poetess

At present, all the best grades in writing literature, which has an important role in maintaining national culture, we are proud to say, have been gained by women. Among the laureats Miss Hi Kimseab, who is also a teacher at the Teacher-training College in B.Bang province, ranked second in the Third Prah Sihanoukraj National Literature Cup contests of 1999.

The First Honor in Life

With a broad smile and wearing an embroidered dark yellow, short-sleeved shirt and an orange-Pharmourng skirt, Miss Hi Kim Seap was holding a silver cup in front of photographers who had been waiting to photograph her. She said with excitement, that it was the first time she had the honor to be ranked second in poetry, in the Third Prah Sihanoukraj National Literature Cup competition held in 1999 and organized by the Association of Khmer Writers under the royal patronage of His Majesty, the King of Cambodia. While walking forward Miss Hi KimSeap went on to say: Although I was not competent enough to be ranked first, I'm still pleased, as I feel that in a competition with so many male candidates, I could compete and succeed as I had long wished.

Her family was not well-off

Miss Hi Kim Seap is a former student of the Prah Monivong Senior High School in B.Bang province. After she completed her studies and received a BacII degree, Miss Hi KimSeap continued her studies at the Faculty of Letters, graduating with a Bachelor's degree. She then continued her studies at the College of Pedagogy and later successfully graduated. She is now a teacher at the Teacher-training College in B.Bang province.

Miss Hi KimSeap further said that when she was studying, her life was fraught with hardships and tests of patience because her family was not well-off. She has two brothers and two sisters and she is the youngest in a family that is fed by a widowed mother and an unmarried elder sister who make "Ako" cakes to sell. She maintained that it was due to her elder sister's sacrifices and all-out efforts, such as not going to school and not getting married,

to provide for her and the entire family, she and the other two elder brothers succeeded in getting through their studies. Miss Hi Kim Seap also attributed her success to the valuable support and assistance of ASPECA, that led her after her father died and assisted in finding her godparents to help support her studies in the last two years. Without them, she would have had to overcome even more serious hardships and difficulties.

This was also confirmed by Mrs Lean Hoy, 64, who is her mother and who expressed deep thanks to ASPECA and Mr CHOLLE MICHELE and Mrs CLAUDIEN, who are both French living in Paris and who are also her daughter's godparents. She thanks them for their valuable support and assistance, without which she would have encountered an even harder life and eventually would have had to dispose of her house to support her children. She said this because she had always thought that, if really forced by circumstances, she would sell the house to enable the children to get through their studies. Nowadays, her three children have jobs. Her son, Iep Ben Loeun, is a doctor in Siem Reap province; Mr Hi Kim Hoeung is an official at the Cabinet Ministers Office and Miss Hi Kim Seap, who is the youngest, is now a teacher.

She prefers reading and studying

Miss Hi Kim Seap stated that before becoming a writer she had been taught to write poetry by Professor Chey Chap, the Under-secretary of State for Education, Youth and Sports. She also attended refresher courses on writing, conducted by the Association of Khmer Writers, with Mr Yubo, Mr Chea Soy, Mr Khieu Sophal, Mr Chhoy Yiheang, Mrs Khlot Thida, H.E Yok Kun, Mr Va Sam Ath and Mr Ven Son as teachers and seniors, and was given specific advice by Mr Un Sok Heang during their conversations together. In addition to what has been mentioned above, Miss Hi Kim Seap prefers reading books on the art of writing poems by Mr Pich Tum Kravel, and the poetry books published by the Ministry of Education. She further contended that reading as many books as possible was also part of the improvement which made her the writer she is today. She said she had written a series of poems entitled "A Bitter Past" and had submitted them to the Association of Khmer Writers in the course of competitions, but had failed to be ranked. Only this time did she actually succeed.

Miss Hi Kim Seap attributed her success in becoming a writer in modern society to her in de fatigable efforts and painful experiences and struggle in life. As a young female writer, she said she would do her best to improve the contents of her poems for the sake of educating so cietyas a whole.

Miss Seng Samnang, aged 25 and a teacher at the Taing Krasaing Senior High School in Kg. Thom province, and who was also a fellow-student of Miss Hi Kim Seap, said Miss Kim Seap was gentle, quiet, friendly to all in general, and very hard-working in her studies. Despite this, Miss Kim Seap is not yet satisfied with her achievements.

Her had wished to enhance national leterature and culture

Miss Hi Kim Seap said the reason why she decided to join such contests was because she had wished to enhance national literature and culture, thereby contributing to diminishing the influence on Khmer Youth of the inappropriate culture and civilization of some foreign countries. Meanwhile, she also wished to raise the ever-decreasing reputation of Khmer women caused by sex-trafficking and duping into prostitution, which make many Khmer girls' experience constant crises and dangers.

The novel that was submitted for competition entitled "The Fate of an Unfortunate Flower (=girl)." It tells about the real life of a girl who was sold, like a beast, into prostitution. She also added some creative ideas to the story to make it more attractive and exciting, and to give it a powerful ending. This novel is written in poem and contains 126 pages. Miss Hi Kim Seap would like to ask everyone, including the Royal Government, to pay great attention to the problems of human abduction and sex-trafficking and to take necessary measures to effectively prevent such problems, so as to help restore and improve the situation of Khmer Women.

Ms Yim Nimola